ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ
# ឆ្នាំ ២០១៤ - ២០១៨


រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



ខែ មិថុនា ឆ្នាំ ២០១៤

# មាតិការឿង


*អារម្ភកថា*

*សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ១០៨ សសរ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីយុទ្ធសាស្ត្រ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨*

*១- សេចក្តីផ្តើម* 1

*២- កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍: សមិទ្ធផល បញ្ហាប្រឈម និងកាលានុវត្តភាព* 2

*៣- ទិសដៅជាយុទ្ធសាស្ត្រ* 6

*៤- គោលការណ៍ ឧបករណ៍ និងភាពជាដៃគូ សម្រាប់អនុវត្តយុទ្ធសាស្ត្រ* 6

ក- គោលការណ៍ 7

ខ- ឧបករណ៍ 8

គ- ភាពជាដៃគូសម្រាប់គាំទ្រភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ 13

*៥- យន្តការពិគ្រោះយោបល់ និងភាពជាដៃគូ* 15

ក- វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា 16

ខ- គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ 17

គ- ក្រុមការងារបច្ចេកទេសចម្រុះ 17

ឃ- កិច្ចពិគ្រោះយោបល់ទ្វេភាគី 18

ង- កិច្ចពិគ្រោះយោបល់ជាមួយវិស័យឯកជន 18

ច- កិច្ចពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល 19

*៦- យន្តការស្ថាប័ន* 19

*៧- ការតាមដាន និងវាយតម្លៃ* 21

ក- ការផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍កម្រិតជាតិ និងកម្រិតវិស័យ 21

ខ- ការតាមដានភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ 22

គ- វិធីសាស្ត្រសម្រាប់រៀបចំរបាយការណ៍ស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយតម្លាភាព 24

ឃ- ការវាយតម្លៃពាក់កណ្តាលអាណត្តិ 25

ង- ការតាមដាននៅកម្រិតវិស័យ និងគម្រោង 25

*៨- សន្និដ្ឋាន* 26

# អារម្ភកថា

វឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមក ក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ សង្គម- សេដ្ឋកិច្ច និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា គឺជាសក្ខីភាពឆ្លុះបញ្ចាំងអំពីភាពជាម្ចាស់ និងសមត្ថភាព របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ជីវភាពសង្គម- សេដ្ឋកិច្ចនៅកម្ពុជា ។ ទន្ទឹមនឹងនេះ ការចូលរួមរបស់បណ្តាគូអង្គ អភិវឌ្ឍន៍ បានបំពេញបន្ថែមដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការពន្លឿនវឌ្ឍនភាព ដើម្បីសម្រេចឱ្យបាន នូវ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។ ក្នុងកិច្ចប្រជុំពេញអង្គលើកដំបូងរបស់គណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី ៥ នៃ រដ្ឋសភា នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ដើម្បីប្រកាសដាក់ឱ្យអនុវត្តនូវ**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី៣ ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះ រាជាណាចក្រកម្ពុជា** បានគូសបញ្ជាក់ពីតម្រូវការក្នុងការបន្តពង្រឹងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ដើម្បីបន្តពង្រឹង សមិទ្ធផលបន្ថែមទៀត និងដោះស្រាយបញ្ហាប្រឈម ព្រមទាំងក្តាប់ឱ្យជាប់នូវកាលានុវត្តភាពថ្មីៗ ក្នុងជវភាពនៃតំបន់ និងសកលលោក ។

ដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ ដូចមានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី៣** រាជរដ្ឋាភិបាលប្តេជ្ញាបន្តអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ គោលនយោបាយ និងយុទ្ធសាស្ត្រទាំងនេះ ក៏បានរំលេចអំពីក្របខណ្ឌសម្រាប់តាមដានលទ្ធផល និងការប្តេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការ ជំរុញភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ។ ទន្ទឹមនឹងការបន្តពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំក្នុងកិច្ចអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានចូលរួមក្នុងកម្រិតសកល ជាមួយគូអង្គអភិវឌ្ឍន៍ដទៃទៀត ដើម្បីរៀបចំ **សេចក្តីថ្លែងការណ៍ទីក្រុងប៊ូសាន ស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍** ។ រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តគោលការណ៍ និងសកម្មភាពនានា ដែលមាន ចែងក្នុងសេចក្តីថ្លែងការណ៍នេះ ដោយផ្អែកលើបរិការណ៍កម្ពុជា ដើម្បីឆ្លើយតបនឹងតម្រូវការពិតប្រាកដក្នុងកិច្ចអភិវឌ្ឍន៍ របស់កម្ពុជា។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានរៀបចំ **យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ** ដើម្បីជំរុញ**ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍** ក្នុងបរិការណ៍កម្ពុជា ដោយរំលេចអំពីបណ្តាសកម្មភាពអាទិភាពដែលត្រូវអនុវត្ត សម្រាប់បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងបានកំណត់របៀបរបបការងារ សម្រាប់ឆ្នាំ ២០១៤- ២០១៨ ។

គោលដៅចម្បងនៃ**យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ** នេះ គឺការលើកកម្ពស់**ភាព ស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍** ។ ជំនួសឱ្យ**ក្របខណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ឆ្នាំ ២០០៦- ២០១០** យុទ្ធសាស្ត្រថ្មីនេះ បានកំណត់អំពីទិសដៅ និងគោលដៅ ព្រមទាំងឧបករណ៍នានា សម្រាប់គ្រប់គ្រងកិច្ច សហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ក៏ដូចជាកំណត់អភិក្រម សម្រាប់អនុវត្ត និងតាមដានបណ្តាសកម្មភាពនៃកិច្ច សហប្រតិបត្តិការអភិវឌ្ឍន៍របស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលរួមមាន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងដៃគូក្នុង ក្របខណ្ឌនៃ**កិច្ចសហប្រតិបត្តិការត្បូង- ត្បូង** ។

ក្រោមការណែនាំផ្ទាល់របស់ខ្ញុំ **យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ** នេះ ត្រូវបាន រៀបចំ តាមរយៈការគ្រប់គ្រងនិងសម្របសម្រួលរបស់**ឯកឧត្តមរដ្ឋមន្ត្រី ឈៀង យ៉ាណារ៉ា** ក្នុងបរិការណ៍ដែលកិច្ចអភិវឌ្ឍន៍

កម្ពុជាកំពុងវិវត្តន៍ឈានឡើង ។ លើមូលដ្ឋាននេះ ការរៀបចំយុទ្ធសាស្ត្រនេះ ត្រូវបានដំណើរការ តាមរយៈកិច្ចពិគ្រោះយោបល់ជាច្រើនលើក ជាមួយភាគីពាក់ព័ន្ធ និងបានផ្អែកលើសក្ខីកម្ម បទពិសោធន៍ និងទស្សនវិស័យ របស់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងរយៈពេលអនុវត្តកន្លងមក នៅតាមវិស័យនានា ដើម្បីឈានទៅឯកភាពលើបណ្តាអាទិភាព ដែលត្រូវបន្តអនុវត្តនាពេលអនាគត ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តសកម្មភាពនានា ដោយផ្អែកលើគោលការណ៍ និងឧត្តមានុវត្តន៍ល្អៗស្តីពីភាពជាដៃគូ ។ រាជរដ្ឋាភិបាលមានជំនឿជឿជាក់យ៉ាងមុតមាំថា ផ្អែកតាមអភិក្រមក្នុងការរៀបចំយុទ្ធសាស្ត្រនេះគួបផ្សំនឹងក្របខណ្ឌលម្អិតសម្រាប់អនុវត្ត និងតាមដាន យុទ្ធសាស្ត្រថ្មីនេះ ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុម័ត តាមរយៈសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ១០៨ សសរ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ នឹងជួយជំរុញឱ្យកម្ពុជាឈានទៅសម្រេចគោលដៅអាទិភាពក្នុងកិច្ចអភិវឌ្ឍន៍ សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គាត ឈន់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០៧ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤ - ២០១៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យអនុវត្តនូវ **យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨** ដូចមានឯកសារភ្ជាប់នឹងសេចក្តីសម្រេចនេះ ដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ។

**ប្រការ ២.-**

ប្រគល់ភារកិច្ចជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់** អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួល និងតាមដានការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ

២០១៤-២០១៨ នេះ ហើយត្រូវធ្វើរបាយការណ៍ពាក់កណ្តាលអាណត្តិ ស្តីពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យ និងផ្តល់អនុសាសន៍ ។

**ប្រការ ៣.-**

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) ក្រោមការគ្រប់គ្រងរបស់ឯកឧត្តម **ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋាន សម្រាប់ដឹកនាំការអនុវត្តយុទ្ធសាស្ត្រនេះ ដោយត្រូវសហការជាមួយបណ្តាក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ក៏ត្រូវជំរុញ និងលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត អនុវត្តខ្លឹមសារនៃយុទ្ធសាស្ត្រនេះ ។ លេខាធិការដ្ឋានត្រូវរាយការណ៍អំពីវឌ្ឍនភាពការងារ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់** ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤ «ដើម្បីអនុវត្ត»*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

## ១-  សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលទទួលស្គាល់ អំពីតួនាទីសំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការជំរុញកិច្ចអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ច និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា ស្របតាមគោលដៅអភិវឌ្ឍន៍ ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើន ក្នុងការអនុវត្ត**ក្របខណ្ឌយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ឆ្នាំ ២០០៦-២០១០** ។ សមិទ្ធផលទាំងនេះត្រូវបានឆ្លុះបញ្ចាំង តាមរយៈកំណើននៃទំហំហិរញ្ញប្បទាន ដែលរាជរដ្ឋាភិបាលបានកៀរគរ ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការវិភាជន៍ និងការប្រើប្រាស់ហិរញ្ញប្បទាន ព្រមទាំងការពង្រឹងយន្តការពិគ្រោះយោបល់ និងការលើកកម្ពស់គុណភាពនៃភាពជាដៃគូ ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ។ ស្ដែងចេញពីភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ហិរញ្ញប្បទានក្រៅប្រទេសទាំងអស់ បានរួមចំណែក ក្នុងការឈានទៅសម្រេចនូវគោលដៅអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ចកម្ពុជា ។

រាជរដ្ឋាភិបាលជឿជាក់ថា កម្ពុជាកំពុងស្ថិតលើមាគ៌ាដ៏ត្រឹមត្រូវ ឆ្ពោះទៅរកវិបុលភាព និងវឌ្ឍនភាព ដែលពុំធ្លាប់មានពីមុន ក្នុងប្រវត្តិសាស្ត្រ ។ កំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក បានធ្វើឱ្យចំណូលរបស់ប្រជាជនម្នាក់ៗ កើនឡើងជិត ៣ ដង ហើយកម្ពុជាកំពុងធ្វើដំណើរយ៉ាងស្វាហាប់ ក្នុងការឈានឡើងពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងអនាគតដ៏ខ្លីខាងមុខនេះ ។ សមិទ្ធផលទាំងនេះមិនមែនសម្រេចបាន ដោយគ្មានបញ្ហាប្រឈមនោះឡើយ ហើយរាជរដ្ឋាភិបាលបានប្ដេជ្ញាបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ក្នុងគោលដៅបន្តពង្រឹងវឌ្ឍនភាពដែលសម្រេចបានកន្លងមក ។ ទន្ទឹមនឹងនេះ បញ្ហាប្រឈមទាំងនេះក៏ជាមូលដ្ឋានសំខាន់ សម្រាប់កំណត់ទិសដៅ និងសកម្មភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ នាអនាគត ។ ទិសដៅចម្បងរបស់រាជរដ្ឋាភិបាល គឺការឈានឡើងជាជំហានៗ ពី**ភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ** ទៅ **ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍** ។ គោលដៅចម្បងនៃ «ភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ» គឺការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងការពង្រឹងសមត្ថភាពជាតិ ដែលផ្ដោតជាសំខាន់ ទៅលើទិដ្ឋភាពបច្ចេកទេសនៃការគ្រប់គ្រងគម្រោង ព្រមទាំងការពង្រឹងទំនាក់ទំនងជាមួយបណ្ដាដៃគូអភិវឌ្ឍន៍ ។ ផ្អែកលើមេរៀន និងបទពិសោធន៍កន្លងមក «ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍» តម្រូវឱ្យផ្ដោតការយកចិត្តទុកដាក់ ទៅលើការសម្រេចឱ្យបាន **លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍** ការពង្រឹងស្ថាប័ននិងសមត្ថភាពជាតិ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ក្នុងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព សំដៅឈានទៅសម្រេច នូវគោលដៅអភិវឌ្ឍន៍ជាតិ ។

លើមូលដ្ឋាននៃវឌ្ឍនភាព និងបញ្ហាប្រឈម ក៏ដូចជាកាលានុវត្តភាពរបស់កម្ពុជាក្នុងជីវភាពថ្មីនៃតំបន់ និងសកលលោក «**យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨**» បានកំណត់គោលដៅច្បាស់លាស់ គឺការជំរុញ «ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍» ។ ក្នុងស្មារតីនេះ យុទ្ធសាស្ត្រដែលបានឆ្លុះបញ្ចាំងអំពីការប្ដេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តឱ្យបានសម្រេចនូវគោលដៅខាងលើ នឹងផ្ដល់ការណែនាំ និងការគាំទ្រដល់បណ្ដាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា ដើម្បីបង្កើនភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងទម្រង់ហិរញ្ញប្បទានដទៃទៀត សម្រាប់រយៈពេលចំពោះមុខ និងរយៈពេលវែង ។

## ២-	កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍: សមិទ្ធផល បញ្ហាប្រឈម និងកាលានុវត្តភាព

សមិទ្ធផលក្នុងបណ្ដាឆ្នាំចុងក្រោយនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់បន្តពង្រឹងវឌ្ឍនភាពបន្ថែមទៀត ទន្ទឹមនឹងបន្តដោះស្រាយបញ្ហាប្រឈម និងក្ដាប់ឱ្យជាប់ នូវកាលានុវត្តភាព សម្រាប់បង្កើនភាពស័ក្ដិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងបណ្ដាសមិទ្ធផលសំខាន់ៗដែលសម្រេចបានកន្លងមក រាជរដ្ឋាភិបាលបានកៀរគរធនធានហិរញ្ញប្បទានសហប្រតិបត្តិការ ប្រមាណជាង ១ ០០០លានដុល្លារ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០០៨ សម្រាប់កិច្ចអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ច ។ ហិរញ្ញប្បទានសហប្រតិបត្តិការនេះ ដែលមានទំហំប្រមាណ ១០% នៃផលិតផលសរុបក្នុងស្រុក បានរួមចំណែកក្នុងការសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ។ ជាលទ្ធផល ចំណូលរបស់ប្រជាជនម្នាក់ៗ បានកើនឡើងពី ៧៦០ដុល្លារ ក្នុងឆ្នាំ ២០០៨ ដល់ជិត ១ ០០០ដុល្លារ ក្នុងឆ្នាំ ២០១២ ។ រីឯអត្រាភាពក្រីក្រ បានធ្លាក់ចុះពី ៤៧,៨% ក្នុងឆ្នាំ ២០០៧ មកនៅត្រឹម ១៩,៨% ក្នុងឆ្នាំ ២០១១ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាចំនួន ៤ មុនកាលបរិច្ឆេទកំណត់ ។ រីឯគោលដៅ ៤ ទៀត កម្ពុជានឹងអាចសម្រេចបានតាមកាលបរិច្ឆេទកំណត់ នៅដំណាច់ឆ្នាំ ២០១៥ ។ កំណើននៃទំហំហិរញ្ញប្បទានសហប្រតិបត្តិការមិនត្រឹមតែបានឆ្លុះបញ្ចាំងអំពីទំនុកចិត្តរបស់សហគមន៍ដៃគូអភិវឌ្ឍន៍ មកលើកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ និងកម្មវិធីកែទម្រង់ប៉ុណ្ណោះទេ ប៉ុន្តែ បានចូលរួមពង្រឹងបរិស្ថានអនុគ្រោះ សម្រាប់ការវិនិយោគ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន ពិសេសក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ កាត់ដេរ កសិកម្ម សំណង់ និងទេសចរណ៍ ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលពិតជាអាចបន្តជំរុញ ឱ្យមានកំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចខ្ពស់នាបណ្ដាឆ្នាំខាងមុខ ដែលអាចនាំកម្ពុជាឈានឡើង ទៅជាប្រទេសមានចំណូលមធ្យម ក៏ដូចជាចូលរួម និងទាញយកអត្ថប្រយោជន៍ពីគំនិតផ្ដួចផ្ដើមនៃការធ្វើសមាហរណកម្មក្នុងតំបន់ និងពិភពលោក ។

សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការបានកើនឡើង ទន្ទឹមនឹងការបង្កើន និងការពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្ត នូវក្របខណ្ឌគោលនយោបាយ រចនាសម្ព័ន្ធខាងស្ថាប័ន យន្តការពិគ្រោះយោបល់ និងភាពជាដៃគូសម្រាប់តម្រែតម្រង់ និងសម្របសម្រួលការវិភាជន៍ហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្របខណ្ឌគោលនយោបាយរចនាសម្ព័ន្ធ និងយន្តការទាំងនេះ ត្រូវបានពិនិត្យ កែលម្អ និងពង្រឹងបន្ថែមជាបន្តបន្ទាប់ ហើយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធដទៃទៀត បានផ្ដល់សារៈសំខាន់ដល់កិច្ចប្រឹងប្រែងរួមគ្នា ដើម្បីពង្រឹងគុណភាពនៃភាពជាដៃគូ និងលើកកម្ពស់ភាពស័ក្ដិសិទ្ធិនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ។ នៅកម្រិតគោលនយោបាយ និងស្ថាប័ន ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ត្រូវបានឆ្លុះបញ្ចាំង តាមរយៈការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការផ្ទេរពី**កិច្ចប្រជុំពិគ្រោះយោបល់** ទៅជា**វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា** ចាប់ពីឆ្នាំ ២០០៧ ដោយរក្សាបាននូវកិត្តិនាម និងគុណភាពនៃកិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ នៅកម្រិតវិស័យវិញ ក្រសួងនិងស្ថាប័ន បានរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ ផែនការ និងយន្តការការងារដែលបានស្ដែងឡើង តាមរយៈយន្តការសម្របសម្រួល និងការរៀបចំក្របខណ្ឌចំណាយ សម្រាប់តម្រង់ទិសក្នុងការប្រើប្រាស់ធនធាននៅកម្រិតវិស័យ និងនៅថ្នាក់ក្រោមជាតិ ។

រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពជាច្រើនគួរឱ្យកត់សម្គាល់ ក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ។ ជាលទ្ធផល កម្ពុជាត្រូវបានទទួលស្គាល់ថា ជាប្រទេសគំរូ និងឈានមុខ នៅតំបន់អាស៊ី- ប៉ាស៊ីហ្វិក ក្នុងការអនុវត្តការប្តេជ្ញានានាស្តីពីភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលមានចែងក្នុង**សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស** នាឆ្នាំ ២០០៥ ហើយដែលត្រូវបានបញ្ជាក់សារជាថ្មី នៅក្នុង**ផែនការសកម្មភាពទីក្រុងអាក្រា** នាឆ្នាំ ២០០៨ ។ ក្នុងស្មារតីនេះ យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាក្របខណ្ឌគោលនយោបាយដ៏សំខាន់ សម្រាប់តម្រឹមធនធានក្រៅប្រទេស ជាមួយអាទិភាពអភិវឌ្ឍន៍កម្ពុជា ។ តម្លាភាពនៃលំហូរ និងនៃការប្រើប្រាស់ធនធានក្រៅប្រទេស ត្រូវបានកែលម្អ តាមរយៈការកត់ត្រា និងការធ្វើបច្ចុប្បន្នភាពព័ត៌មានជាប្រចាំ ក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ ចំពោះសុខដុមនីយកម្មវិញ រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលគួរជាទីមោទនៈ តាមរយៈការរៀបចំ និងការដាក់ឱ្យអនុវត្ត នូវឧបករណ៍មួយចំនួនពិសេស អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ផែនការប្រតិបត្តិការប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា ព្រមទាំងវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ លើសពីនេះ ក្របខណ្ឌលទ្ធផលត្រូវបានរៀបចំ និងរំលេចក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយត្រូវបានកែលម្អជាបន្តបន្ទាប់ ដើម្បី ក្លាយជាក្របខណ្ឌគ្រប់ជ្រុងជ្រោយ សម្រាប់តាមដាន និងវាយតម្លៃលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានកន្លងមក រាជរដ្ឋាភិបាលបានជួបបញ្ហាប្រឈមមួយចំនួនក្នុងការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការប្តេជ្ញារបស់ភាគីពាក់ព័ន្ធ ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងតួអង្គអភិវឌ្ឍន៍ ពិតជាមានសារៈសំខាន់ ដើម្បីបន្តអនុវត្ត**របៀបវារៈនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដែលមិនទាន់បានអនុវត្ត** ក្នុងគោលដៅបង្កើនភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ ពិសេស តាមរយៈការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដើម្បីតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយនឹងបណ្តាអាទិភាពរបស់កម្ពុជា និងដើម្បីធ្វើសុខដុមនីយកម្មហិរញ្ញប្បទានរបស់បណ្តាដៃគូអភិវឌ្ឍន៍ ព្រមទាំងអភិវឌ្ឍសមត្ថភាព សម្រាប់កែលម្អការគ្រប់គ្រងវិស័យសាធារណៈ ។ ទន្ទឹមនឹងនេះ ក្នុងការសម្រេចឱ្យបាន**លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍** រាជរដ្ឋាភិបាលនឹងបន្តកសាង និងពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ព្រមទាំងបន្តពង្រឹងប្រព័ន្ធជាតិស្របតាមការប្តេជ្ញានានា ដែលបានឯកភាពក្នុងវេទិកាកំពូល នៅទីក្រុងប៊ូសាននៃសាធារណរដ្ឋកូរ៉េ នាចុងឆ្នាំ ២០១១ ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង និងពង្រីកបន្ថែមទៀត នូវវឌ្ឍនភាពដែលសម្រេចបានកន្លងមក ក្នុងកម្មវិធីកែទម្រង់វិស័យសាធារណៈ ដូចជា កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់តាមបែបប្រជាធិបតេយ្យនៅ

**<u>សមិទ្ធផលនៃភាពជាដៃគូ</u>**

***<u>ភាពជាម្ចាស់ក្នុងកិច្ចអភិវឌ្ឍន៍</u>*** : រាជរដ្ឋាភិបាលបានកំណត់អាទិភាពច្បាស់លាស់សម្រាប់អនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងបានតម្រឹមធនធានសហប្រតិបត្តិការ ជាមួយនឹងអាទិភាពនៃកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូ ។

***<u>ការអភិវឌ្ឍសមត្ថភាព</u>*** : រាជរដ្ឋាភិបាលបានពង្រឹងសមត្ថភាព ក្នុងការដឹកនាំ និងគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

***<u>ការតម្រឹម</u>*** : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ គឺជាមូលដ្ឋានសំខាន់ សម្រាប់តម្រែតម្រង់ការវិភាជន៍ធនធានប្រកបដោយប្រសិទ្ធភាព ។

***<u>សុខដុមនីយកម្ម</u>*** : រាជរដ្ឋាភិបាលបានបង្កើត និងបានដាក់ឱ្យអនុវត្តយន្តការពិគ្រោះយោបល់ និងភាពជាដៃគូ ។

***<u>ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល</u>*** : កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុវត្តអភិក្រមនេះ ក្នុងដំណើរការវិភាជន៍ថវិកា ។ រីឯសូចនាករតាមដានរួមគ្នាក៏ត្រូវបានរៀបចំឡើងវិញ និងកែលម្អជាបន្តបន្ទាប់ ។

ថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសង្គតិភាព ក្នុងដំណើរការនៃការអនុវត្ត បណ្តាអាទិភាព បង្កើនសមត្ថភាព និងពង្រឹងប្រព័ន្ធ និងនីតិវិធីជាតិ ព្រមទាំងធានាគណនេយ្យភាពចំពោះលទ្ធផល ដែលសម្រេចបាន ។

ម្យ៉ាងវិញទៀត យន្តការពិគ្រោះយោបល់នៅគ្រប់កម្រិត ក៏បានយកចិត្តទុកដាក់ដល់ភាពសម្បូណ៌បែប និង ការចូលរួមផ្សេងៗគ្នារបស់តួអង្គនីមួយៗ ដោយគោរពបាន នូវគោលការណ៍ស្តីពីភាពជាម្ចាស់របស់កម្ពុជា និងការ ផ្តោតលើ**លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍** ព្រមទាំងការធានាចីរភាពក្នុងការអភិវឌ្ឍសមត្ថភាព និងស្ថាប័ន ។ ទន្ទឹមនឹងនេះ យន្តការពិគ្រោះយោបល់ ក៏បានដំណើរការ ក្នុងស្មារតីនៃភាពជាដៃគូប្រកបដោយបរិយាប័ន្ន ។ លើសពីនេះ ការពិគ្រោះ យោបល់របស់ក្រុមការងារនីមួយៗ និងរវាងក្រុមការងារទាំងអស់ ក៏បានដំណើរការល្អប្រសើរជាងមុន ហើយត្រូវបាន បំពេញបន្ថែមដោយយន្តការពិគ្រោះយោបល់ទ្វេភាគី ទាំងផ្លូវការនិងមិនផ្លូវការ ដូចធ្លាប់អនុវត្តកន្លងមក ដើម្បីបន្តជំរុញ និងធានាសង្គតិភាពខាងគោលនយោបាយ និងបន្តអនុវត្តកម្មវិធីតាមវិស័យ និងកម្មវិធីកែទម្រង់ ឱ្យសកម្មបន្ថែមទៀត ។

វិបត្តិកលិយុគហិរញ្ញវត្ថុ និងការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក ដែលបានជះឥទ្ធិពលដល់ការផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការ និងភាពប្រកួតប្រជែងនៃការប្រើប្រាស់ទម្រង់ថ្មីៗក្នុងការផ្តល់ហិរញ្ញប្បទាន ដូចជាមូលនិធិសកល ជាដើម អាចធ្វើឱ្យទំហំហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍មួយចំនួន មានការធ្លាក់ចុះ សម្រាប់រយៈពេលមធ្យម ។ ក្នុង បរិការណ៍នេះ កម្ពុជានឹងប្រឹងប្រែងស្វែងរកធនធានពីប្រភពដទៃទៀត ក៏ដូចជាប្រឹងប្រែងឱ្យអស់លទ្ធភាពក្នុងការ ប្រមូលចំណូលក្នុងស្រុក សម្រាប់បន្តអភិវឌ្ឍប្រទេស និងពង្រឹងសមិទ្ធផលសង្គម- សេដ្ឋកិច្ច ដែលសម្រេចបានកន្លង មក ។ ទន្ទឹមនឹងនេះ សមាហរណកម្មក្នុងតំបន់ រួមទាំងសហគមន៍សេដ្ឋកិច្ចអាស៊ាន នាឆ្នាំ ២០១៥ ក៏បានបង្កើតបញ្ហា ប្រឈមផង និងបានផ្តល់កាលានុវត្តភាពថ្មីៗផង ដល់កម្ពុជា ។ ក្នុងបរិការណ៍នេះ តួអង្គអភិវឌ្ឍន៍ទាំងអស់ត្រូវបន្ត សហការជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីពង្រឹងសមត្ថភាព និងប្រព័ន្ធជាតិ សម្រាប់កែលម្អការផ្តល់សេវាសាធារណៈ និងបង្កើនសមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ចរបស់កម្ពុជា ។

សម្រាប់រយៈពេលមធ្យម ទន្ទឹមនឹងបញ្ហាប្រឈមដូចបានជម្រាបខាងលើ កម្ពុជាក៏មានកាលានុវត្តភាពជាច្រើន សម្រាប់បន្តពង្រឹង និងពង្រីកវឌ្ឍនភាពដែលសម្រេចបានកន្លងមក ក្នុងការលើកកម្ពស់ភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទាន សហប្រតិបត្តិការ សំដៅជំរុញភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរឡើង ។ មាគ៌ាឈានឡើងរបស់កម្ពុជា ពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងអនាគតដ៏ខ្លីខាងមុខនេះ នឹងធ្វើឱ្យមាន បម្រែបម្រួលក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការមកកម្ពុជា ។ ទោះបីត្រូវប្រឈមនឹងការធ្លាក់ចុះនៃហិរញ្ញប្បទាន សហប្រតិបត្តិការ ទាំងហិរញ្ញប្បទានឥតសំណង ទាំងហិរញ្ញប្បទានជាកម្ចី ក៏ដោយ ក៏កម្ពុជាមានកាលានុវត្តភាព ជាច្រើន ក្នុងការទទួលហិរញ្ញប្បទានពីប្រភពថ្មី និងតាមទម្រង់ថ្មី បន្ថែមទៀតដែរ ។

វត្តមានកាន់តែច្រើនឡើងរបស់**ដៃគូអភិវឌ្ឍន៍មិនប្រពៃណី** ពិសេស ពីតំបន់អាស៊ី និងប៉ាស៊ីហ្វិច និងទម្រង់ ប្រកបដោយគំនិតច្នៃប្រឌិត ដូចជា **កិច្ចសហប្រតិបត្តិការត្បូង- ត្បូង** ពីប្រទេសធ្លាប់មានប្រវត្តិទទួលហិរញ្ញប្បទាន សហប្រតិបត្តិការកន្លងមក និងទម្រង់ហិរញ្ញប្បទានថ្មីៗដទៃទៀតដែលបានបង្កើតឡើង សម្រាប់ដោះស្រាយបញ្ហា

ប្រឈម ក្នុងកម្រិតតំបន់ និងសកលលោក ដូចជា ការប្រែប្រួលអាកាសធាតុ បានផ្តល់នូវការគិតគូរ និងអភិក្រម ព្រមទាំងប្រភពធនធានថ្មីៗ ដល់កម្ពុជា ។ ជាមួយគ្នានេះ វិស័យឯកជន ដែលជាប្រតិបត្តិករសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល នឹងបន្តពង្រឹងកិច្ចសហការ ជាមួយនឹងរាជរដ្ឋាភិបាល នាពេលអនាគត ។ លើមូលដ្ឋាន នៃភាពសម្បូណ៌បែបរបស់តួអង្គអភិវឌ្ឍន៍ និងកាលានុវត្តភាពដូចបានរៀបរាប់ខាងលើ កិច្ចអភិវឌ្ឍន៍កម្ពុជា ត្រូវផ្អែក លើទស្សនៈទូលំទូលាយជាងមុន ពោលគឺ មិនផ្អែកលើតែហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ប្រពៃណីនោះឡើយ ។

លើមូលដ្ឋាននេះ ក្រោមភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយ ប្រសិទ្ធភាព នឹងយកចិត្តទុកដាក់ដល់ភាពសម្បូណ៌បែប របស់ភាគីពាក់ព័ន្ធ និងទម្រង់ច្នៃប្រឌិតថ្មីៗ ព្រមទាំងផ្តល់តម្លៃ ដល់ការចូលរួមរបស់តួអង្គអភិវឌ្ឍន៍នីមួយៗ ដើម្បីឈានទៅសម្រេចគោលដៅរួមនៃកិច្ចអភិវឌ្ឍន៍ ក្នុងបរិការណ៍នៃ ភាពជាដៃគូប្រកបដោយបរិយាប័ន្ន ។ ដើម្បីប្រើប្រាស់ឱ្យអស់សក្តានុពល និងផ្អែកលើភាពសម្បូណ៌បែបរបស់ដៃគូ អភិវឌ្ឍន៍ និងហិរញ្ញប្បទានរបស់ពួកគេ រាជរដ្ឋាភិបាលនឹងបន្តស្វែងយល់បន្ថែមទៀត និងគ្រប់គ្រងឱ្យបានអំពីរបៀប របបដំណើរការ និងប្រភពធនធានរបស់តួអង្គនីមួយៗ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន សម្រាប់ធ្វើជា មូលដ្ឋាននៃការកំណត់គោលដៅ និងតាមដានលទ្ធផល ក្នុងបរិការណ៍នៃអភិក្រមស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ។

សរុបមក ការពិនិត្យឡើងវិញអំពីសមិទ្ធផល បញ្ហាប្រឈម និងកាលានុវត្តភាព បានបង្ហាញយ៉ាងច្បាស់ថា បរិការណ៍នៃការអភិវឌ្ឍកម្ពុជា ក៏ដូចជាសកលលោក តម្រូវឱ្យរាជរដ្ឋាភិបាលបន្តផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្ពស់ ទៅលើការសម្រេចឱ្យបាននូវលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ និងការប្រើប្រាស់អភិក្រមនានាដែលគាំទ្រដល់ផែនការនីយកម្ម ភាពជាដៃគូ និងការតាមដាន ។ ក្នុងស្មារតីនេះ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ត្រូវ ផ្សារភ្ជាប់ និងត្រូវផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ។ ដើម្បីអនុវត្តអភិក្រមស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ច អភិវឌ្ឍន៍ សកម្មភាពទាំងឡាយសម្រាប់ពង្រឹងភាពជាដៃគូ និងសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹង សមត្ថភាពប្រកបដោយចីរភាព ត្រូវតែផ្សារភ្ជាប់នឹងក្របខណ្ឌផែនការ ក្របខណ្ឌថវិកា និងក្របខណ្ឌតាមដានលទ្ធផល របស់កម្ពុជា ។ ទន្ទឹមនឹងនេះ ដៃគូអភិវឌ្ឍន៍ក៏ត្រូវប្រើប្រាស់ហិរញ្ញប្បទានរបស់ខ្លួន សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធី កែទម្រង់នានា ក្នុងគោលដៅអភិវឌ្ឍសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ក្របខណ្ឌលទ្ធផលសម្រាប់តាមដាន ក៏ត្រូវបានបង្កើត ទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតវិស័យ សម្រាប់ជំរុញ និងតម្រែតម្រង់ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ឱ្យមានប្រសិទ្ធភាព សំដៅឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។

កម្ពុជានឹងបន្តកិច្ចអភិវឌ្ឍន៍លើមាគ៌ាដ៏ត្រឹមត្រូវរបស់ខ្លួន ដើម្បីពង្រឹងសន្តិភាព ស្ថិរភាព និងវិបុលភាពជូន ប្រជាជន ។ មូលដ្ឋានគ្រឹះដែលរាជរដ្ឋាភិបាលបានកសាងក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក នឹងបន្តពង្រឹង និង លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដោយផ្អែកលើឧត្តមភាពប្រៀបធៀបរបស់ដៃគូនីមួយៗ ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តការប្តេជ្ញារបស់ខ្លួន និងដាក់ឱ្យអនុវត្ត នូវសកម្មភាពជាក់ស្តែងមួយចំនួន សម្រាប់កសាង និងពង្រឹងសមត្ថភាព និងប្រព័ន្ធជាតិ ក៏ដូចជាបន្តគ្រប់គ្រងហានីភ័យ និងក្តាប់ឱ្យជាប់នូវកាលានុវត្តភាព ដើម្បីពង្រឹង ភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ។ ក្នុងន័យនេះ គោលដៅចម្បងនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ

អភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ គឺការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងភាពជាដៃគូ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។

## ៣- ទិសដៅជាយុទ្ធសាស្ត្រ

ដើម្បីបន្តពង្រឹងសមិទ្ធផល និងក្តាប់ឱ្យជាប់នូវកាលានុវត្តភាពថ្មីៗ ព្រមទាំងបន្តដោះស្រាយបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ បានកំណត់គោលដៅចម្បងចំនួន ១ និងទិសដៅជាយុទ្ធសាស្ត្រចំនួន ៣ ។ រាជរដ្ឋាភិបាលបានកំណត់និយមន័យនៃ **ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍** សម្រាប់អនុវត្តក្នុងបរិការណ៍កម្ពុជា និងសម្រាប់តាមដានវឌ្ឍនភាព ក្នុងការអនុវត្តទិសដៅជាយុទ្ធសាស្ត្រនីមួយៗ ដើម្បីសម្រេចគោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានរៀបចំសូចនាករខាងបរិមាណ សម្រាប់តាមដាន ហើយការតាមដាននេះនឹងបំពេញបន្ថែមដោយការវាយតម្លៃ (ផ្នែកទី៧ ស្តីពីការតាមដាន និងវាយតម្លៃ) ។

| គោលដៅចម្បង និងទិសដៅជាយុទ្ធសាស្ត្រ សម្រាប់លើកកម្ពស់ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា | |
|---|---|
| ***គោលដៅចម្បង***: ធនធានសហប្រតិបត្តិការទាំងអស់ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍កម្ពុជា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ និងការដ្ឋានកែទម្រង់ ។ | |
| **<u>ទិសដៅជាយុទ្ធសាស្ត្រទី ១</u>**<br>ធនធានក្រៅប្រទេសត្រូវបានប្រើប្រាស់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងចីរភាពនៃកិច្ចអភិវឌ្ឍន៍ | ការប្តេជ្ញាស្តីពីភាពជាដៃគូកម្រិតសកល ត្រូវបានអនុវត្ត ស្របតាមបរិការណ៍ និងអាទិភាពរបស់កម្ពុជា ។ ការប្រើប្រាស់ធនធានក្នុងប្រទេស និងក្រៅប្រទេស ត្រូវបំពេញឱ្យគ្នាទៅវិញទៅមក សម្រាប់អនុវត្តបណ្តាអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ អាទិភាពតាមវិស័យ និងការដ្ឋានកែទម្រង់ ដែលមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រទេស ។ |
| **<u>ទិសដៅជាយុទ្ធសាស្ត្រទី ២</u>**<br>ភាពជាដៃគូត្រូវផ្តោតលើការអភិវឌ្ឍសមត្ថភាព និងការពង្រឹងប្រព័ន្ធជាតិ | យន្តការស្តីពីភាពជាដៃគូ ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់អភិក្រមនានា ដែលអាចឆ្លើយតបនឹងតម្រូវការអាទិភាពក្នុងការអភិវឌ្ឍសមត្ថភាព និងការពង្រឹងប្រព័ន្ធជាតិ រួមទាំងការអនុវត្តកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ប្រកបដោយភាពប្រទាក់ក្រឡាគ្នា ដើម្បីពង្រឹងសមត្ថភាពប្រកបដោយចីរភាព នៃស្ថាប័នរបស់រាជរដ្ឋាភិបាល ។ |
| **<u>ទិសដៅជាយុទ្ធសាស្ត្រទី ៣</u>**<br>តួអង្គអភិវឌ្ឍន៍ទាំងអស់ នឹងចូលរួមក្នុងយន្តការនៃភាពជាដៃគូ ដើម្បីជំរុញកំណើន ឱ្យបានទូលំទូលាយ និងប្រកបដោយសមធម៌ | ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ និងធនធានរបស់ដៃគូអភិវឌ្ឍន៍ ត្រូវបំពេញតួនាទីជាកាតាលីករ ដើម្បីឈានទៅសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ទន្ទឹមនឹងការជំរុញការប្រើប្រាស់ឱ្យកាន់តែច្រើនឡើង នូវកិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ ព្រមទាំងភាពជាដៃគូជាមួយវិស័យឯកជន ។ វេទនាសម្ព័ន្ធសម្រាប់ពិភាក្សាប្រកបដោយប្រសិទ្ធភាព និងការកែលម្អសូចនាករតាមដានរួមគ្នា ត្រូវផ្តោតលើការសម្រេចឱ្យបានលទ្ធផលដែលបានកំណត់ ។ |

## ៤- គោលការណ៍ ឧបករណ៍ និងភាពជាដៃគូ សម្រាប់អនុវត្តយុទ្ធសាស្ត្រ

ផ្អែកលើមេរៀន និងបទពិសោធន៍ ក្នុងការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងក្នុងការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស កន្លងមក ក៏ដូចជាទស្សនទានទៅអនាគតរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញអនុវត្ត**ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍** ក្នុងបរិការណ៍កម្ពុជា យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ បានកំណត់គោលការណ៍ និងឧបករណ៍មួយចំនួន សម្រាប់ជាមូលដ្ឋានក្នុងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។

## ក- <u>គោលការណ៍</u>

គោលការណ៍ស្នូលដូចខាងក្រោមនេះ នឹងជួយតម្រែតម្រង់រាល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ÷

១- រាជរដ្ឋាភិបាលនឹងដឹកនាំ**ភាពជាដៃគូប្រកបដោយបរិយាប័ន្ន** ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដោយផ្តោតទៅលើការសម្រេចឱ្យបាន**លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍** តាមរយៈការធ្វើការងាររួមគ្នា ទន្ទឹមនឹងការទទួលស្គាល់អំពីភាពសម្បូណ៌បែបរបស់បណ្តាតួអង្គទាំងនេះ ។

២- រាជរដ្ឋាភិបាល និងបណ្តាតួអង្គអភិវឌ្ឍន៍ ប្តេជ្ញាកសាងទំនាក់ទំនងការងារ លើមូលដ្ឋាននៃជំនឿទុកចិត្ត និងការគោរពគ្នាទៅវិញទៅមក តាមរយៈក្របខណ្ឌនៃការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងក្របខណ្ឌនៃការតាមដានប្រកបដោយប្រសិទ្ធភាព ។

៣- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ គឺជាមូលដ្ឋានសម្រាប់គ្រប់តួអង្គអភិវឌ្ឍន៍ វិភាជន៍ធនធាន ធ្វើកម្មវិធីនីយកម្ម និងពិភាក្សា ព្រមទាំងសម្រាប់រៀបចំយន្តការតាមដាន ។ គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវចូលរួមជំរុញកិច្ចអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ច ប្រកបដោយចីរភាព និងសមធម៌ តាមរយៈការបង្កើនសមត្ថភាពផលិត និងការពង្រឹងមូលធនមនុស្សកម្ពុជា ។

៤- គោលការណ៍ទាំងឡាយ ដែលមានចែងក្នុង**សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស** នៅមានភាពសមស្របសម្រាប់បន្តអនុវត្តនៅកម្ពុជា ។ រាជរដ្ឋាភិបាលទទួលយកទម្រង់ហិរញ្ញប្បទានណា ដែលបានពិភាក្សា និងឯកភាពរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្របតាមបទដ្ឋានដែលបានឯកភាពនៅទីក្រុងប៉ារីស (ឆ្នាំ ២០០៥) នៅទីក្រុងអាក្រា (ឆ្នាំ ២០០៨) និងនៅទីក្រុងប៊ូសាន (ឆ្នាំ ២០១១) ។

៥- សុខដុមនីយកម្មក្នុងការគ្រប់គ្រង និងប្រើប្រាស់ហិរញ្ញប្បទាន នៅកម្រិតវិស័យ និងអន្តរវិស័យ នឹងមានភាពកាន់តែប្រសើរឡើង ដោយសារមានដៃគូអភិវឌ្ឍន៍កាន់តែច្រើនឡើងៗ បានឯកភាពអនុវត្តអភិក្រមរួមសម្រាប់កម្មវិធីនីយកម្ម ដូចជា អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ជាដើម ។

៦- ការអភិវឌ្ឍសមត្ថភាព គឺជាគោលដៅសំខាន់មួយនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ជាទូទៅ កិច្ចសហ-ប្រតិបត្តិការបច្ចេកទេស ត្រូវបានផ្តល់ក្នុងក្របខណ្ឌហិរញ្ញប្បទានឥតសំណង សម្រាប់អភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ក្រោមភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្ត **គោលការណ៍ណែនាំស្តីពីតួនាទី និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស** ដែលបានអនុម័ត នាខែ កញ្ញា ឆ្នាំ ២០០៨ ដែលក្នុងនោះ បានចែងច្បាស់ថា ការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេសត្រូវតែមានសង្គតិភាព ជាមួយគោលដៅនៃការអភិវឌ្ឍសមត្ថភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រ ឬផែនការរបស់រាជរដ្ឋាភិបាល ទន្ទឹមនឹងការយកចិត្តទុកដាក់ដល់បរិស្ថានការងារក្នុងពេលអនុវត្តផងដែរ ។ លើសពីនេះ គំនិតផ្តួចផ្តើមនានាសម្រាប់ពង្រឹងសមត្ថភាព និងការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសត្រូវតែផ្សារភ្ជាប់ ជាមួយកម្មវិធីកែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល ។

## ១- ឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រ

រាជរដ្ឋាភិបាលបានកំណត់ឧបករណ៍ និងអភិក្រមសំខាន់ៗចំនួន ៤ សម្រាប់គ្រប់គ្រងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ឱ្យមានប្រសិទ្ធភាព និងសម្រាប់អនុវត្តឱ្យបានសម្រេច នូវទិសដៅនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ឧបករណ៍ និងអភិក្រមនីមួយៗ ដែលបានរៀបចំ និងកំពុងដាក់ឱ្យអនុវត្តកន្លងមក ត្រូវបានរំលេចសារជាថ្មីម្តងទៀត ក្នុងយុទ្ធសាស្ត្រនេះ សម្រាប់បន្តអនុវត្ត និងដកស្រង់បទពិសោធន៍ ព្រមទាំងសម្របតាមបរិស្ថានការងារជាក់ស្តែងនីមួយៗ ដោយផ្អែកលើសមិទ្ធផលដែលសម្រេចបានកន្លងមក ។

### *១- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី*

កម្ពុជាបានទទួលហិរញ្ញប្បទានសហប្រតិបត្តិការ ពីប្រភពជាច្រើន ។ លើមូលដ្ឋាននេះ អភិក្រមនៃភាពជាដៃគូត្រូវទទួលស្គាល់ នូវភាពសម្បូណ៌បែប និងរបៀបអនុវត្តរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។ **អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី** ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត នាខែវិច្ឆិកា ឆ្នាំ ២០១០ គឺជាអភិក្រមដ៏សមស្រប សម្រាប់គ្រប់គ្រងភាពជាដៃគូនៅកម្រិតវិស័យ ស្របតាមបរិការណ៍កម្ពុជា ក្នុងគោលដៅលើកកម្ពស់សង្គតិភាព រវាងគោលនយោបាយនិងការអនុវត្តដោយទទួលស្គាល់ នូវតថភាពនៃភាពខុសៗគ្នាក្នុងកម្មវិធីនីយកម្មរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។

ក្នុងរយៈពេលជិត ៣ ឆ្នាំ នៃការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី រាជរដ្ឋាភិបាលទទួលបានបទពិសោធន៍ល្អៗជាច្រើន សម្រាប់ជាមូលដ្ឋានក្នុងការបន្តពន្លឿនការអនុវត្តអភិក្រមនេះឱ្យមានប្រសិទ្ធភាពបន្ថែមទៀត នាអនាគត÷

- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ទាមទារភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព និងការប្តេជ្ញាខ្ពស់របស់ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងផែនការតាមវិស័យ ។
- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី អាចដំណើរការបានល្អ ប្រសិនបើក្រសួង និងស្ថាប័ននាំមុខ មានសមត្ថភាពគ្រប់គ្រាន់ ទន្ទឹមនឹងការពង្រឹងតួនាទីនៃការងារផែនការ ភាពជាដៃគូ និងការតាមដានវឌ្ឍនភាព ។
- តម្លាភាព និងទំនាក់ទំនងរបស់ដៃគូទាំងអស់ មានសារៈសំខាន់ជាចម្បង ដើម្បីធានាថា រាល់ការសម្រេចក្នុងការរៀបចំ និងអនុវត្តកម្មវិធី និងការតាមដានវឌ្ឍនភាព នឹងរួមចំណែកក្នុងការពង្រឹងលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។
- ជោគជ័យនៃការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ទាមទារឱ្យយកចិត្តទុកដាក់ ដល់ការវាយតម្លៃរួមគ្នាលើសមត្ថភាព និងកិច្ចខិតខំប្រឹងប្រែង សម្រាប់ពង្រឹងប្រព័ន្ធជាតិ ដោយត្រូវធានាឱ្យមានសង្គតិភាពជាមួយកម្មវិធីកែទម្រង់វិស័យសាធារណៈរបស់រាជរដ្ឋាភិបាល ។
- ការអនុវត្តអភិក្រមដែលផ្តោតលើលទ្ធផល និងក្របខណ្ឌតាមដាន គឺជាឧបករណ៍សំខាន់ សម្រាប់តម្រែតម្រង់ទិសក្នុងការផ្តល់ធនធាន និងកិច្ចពិគ្រោះយោបល់ ដោយផ្អែកលើគោលដៅរួមដែលបានឯកភាព ។

បច្ចុប្បន្ន គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ទា/ក.អ.ក) មានសមត្ថភាពបច្ចេកទេស សម្រាប់គាំទ្រក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ក្នុងការបង្កើត ក៏ដូចជាការបន្តពង្រឹងការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី នៅតាមវិស័យនីមួយៗ ។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីរបស់រាជរដ្ឋាភិបាល

បានកំណត់សមាសភាពសំខាន់ៗ ដែលត្រូវបន្តពង្រឹង តាមរយៈអភិក្រមនៃភាពជាដៃគូ ដូចបានបង្ហាញក្នុងក្រាហ្វិចខាងឆ្វេងនេះ ។ អភិក្រមនេះនៅតែរក្សាភាពសមស្របរបស់ខ្លួន សម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ហើយក៏ជាឧបករណ៍សំខាន់ សម្រាប់ឈានទៅសម្រេចគោលដៅនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។




សកម្មភាពគន្លឹះនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលបានកំណត់ ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ មានដូចខាងក្រោម ÷

- ក្រសួង និងក្រុមការងារបច្ចេកទេសចម្រុះ ដោយសហការជាមួយ គ.ជ.ន/ក.អ.ក ត្រូវពិនិត្យឡើងវិញពីការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដើម្បីកំណត់កាលានុវត្តភាព សម្រាប់បន្តជំរុញអភិក្រមនេះ ។
- គ.ជ.ន/ក.អ.ក នឹងបន្តផ្តល់ការគាំទ្របច្ចេកទេស ដល់ក្រុមការងារ ដែលមានបំណងអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ឬពង្រឹងការអនុវត្តសមាសភាពជាក់លាក់ណាមួយនៃអភិក្រមនេះ ។
- ក្រុមការងារបច្ចេកទេសចម្រុះត្រូវកំណត់ឱ្យច្បាស់លាស់ អំពីបញ្ហានានាដែលពាក់ព័ន្ធនឹងភាពជាដៃគូ និងសមត្ថភាព ក្នុងការអនុវត្តអភិក្រមនេះ ដើម្បីធានាថា គ្រប់តួអង្គពាក់ព័ន្ធទាំងអស់បានចូលរួមក្នុងដំណើរការកម្មវិធីនីយកម្ម និងការអភិវឌ្ឍសមត្ថភាពប្រកបដោយចីរភាព នៅកម្រិតវិស័យ ។
- បង្កើនការយកចិត្តទុកដាក់លើការដកស្រង់មេរៀន និងបទពិសោធន៍ ព្រមទាំងការផ្ទេរចំណេះដឹងខាងគោលនយោបាយ តាមរយៈការពិភាក្សា និងការបណ្តុះបណ្តាលក្នុងបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ។

### *២- ក្របខណ្ឌលទ្ធផល និងអភិក្រមដែលផ្តោតលើលទ្ធផល*

ក្នុងការសម្រេចលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានប្តេជ្ញាកែលម្អក្របខណ្ឌ ដើម្បីធានាការផ្សារភ្ជាប់គ្នារវាងគោលនយោបាយ ធាតុចូល សកម្មភាព និងលទ្ធផល (ធាតុចេញ និងលទ្ធផល) ។ ការប្រើប្រាស់ក្របខណ្ឌលទ្ធផលនៅកម្រិតវិស័យ ដែលផ្សារភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងជួយជំរុញឱ្យមានការឯកភាពរួមគ្នា លើសកម្មភាពដែលត្រូវអនុវត្ត (សកម្មភាពអាទិភាព) ក៏ដូចជាសម្រាប់តាមដានវឌ្ឍនភាពដែលសម្រេចបានធៀបនឹងគោលដៅដែលបានកំណត់ (សូចនាករធាតុចេញ និងលទ្ធផល) និងធនធានដែលកៀរគរបាន ។ លើមូលដ្ឋាននេះ ក្របខណ្ឌលទ្ធផល គឺជាឧបករណ៍ដ៏រឹងមាំ សម្រាប់ផ្សារភ្ជាប់ និងសម្របសម្រួល រវាងគោលនយោបាយ និងការប្រើប្រាស់ធនធាន ការអនុវត្តសកម្មភាព និងការតាមដាន ។

ជាក់ស្តែង ក្រុមការងារបច្ចេកទេសចម្រុះ និងវិស័យជាច្រើន បានរៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌលទ្ធផលនេះ ។ ការអនុវត្តក្របខណ្ឌលទ្ធផល របស់បណ្តាក្រុមការងារ និងវិស័យ ជួយសម្រួលដល់ការប្រឹងប្រែងរួមគ្នា ក្នុងការកៀរគរធនធាន ការរៀបចំកម្មវិធីនីយកម្ម និងការតាមដាន ក៏ដូចជាបន្តពង្រឹងសមិទ្ធផល ដែលសម្រេចបាន

កន្លងមក ។ អភិក្រមដូចបានបង្ហាញក្នុងសង្វាក់លទ្ធផលខាងក្រោមនេះ នឹងត្រូវប្រើប្រាស់ សម្រាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការតាមវិស័យ ក្នុងបរិការណ៍នៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងក្របខណ្ឌតាមដានតាមវិស័យ ដើម្បីឆ្លើយតបនឹងតម្រូវការ និងស្ថានភាពជាក់ស្តែងរបស់វិស័យ ឬក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ។

| **ធាតុចូល** → | **សកម្មភាព** → | **ធាតុចេញ** → | **លទ្ធផល** → | **ផលរយៈពេលវែង** |
|---|---|---|---|---|
| ធនធាន | ការអនុវត្ត | ផលិតផល/ សេវា | ការប្រើប្រាស់សេវា | ប្រសិទ្ធភាពនៃការប្រើប្រាស់សេវា |

ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តជំរុញលើកទឹកចិត្តឱ្យក្រុមការងារបច្ចេកទេសចម្រុះ និងវិស័យនីមួយៗ រៀបចំ និងប្រើប្រាស់ក្របខណ្ឌលទ្ធផល និងអភិក្រមដែលមានលក្ខណៈប្រហាក់ប្រហែល ដើម្បីធានាការផ្សារភ្ជាប់ឱ្យកាន់តែល្អប្រសើរឡើង រវាងលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាមួយនឹងកម្មវិធីតាមវិស័យ ក៏ដូចជាជួយសម្រួលដល់ការរៀបចំផែនការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ។ ក្របខណ្ឌលទ្ធផលដែលតម្រូវឱ្យមានកិច្ចសហការរវាងបណ្តាវិស័យ ក៏អាចជួយសម្រួលការពិភាក្សាអន្តរវិស័យ សម្រាប់ធានាឱ្យមានធនធានគ្រប់គ្រាន់ និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្ត ព្រមទាំងពង្រឹងប្រព័ន្ធតាមដាន ។ លើមូលដ្ឋាននេះ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី គឺជារបៀបគ្រប់គ្រងមួយ ដែលអាចឆ្លើយតបនឹងអភិក្រមដែលផ្តោតលើលទ្ធផល ។

សកម្មភាពគន្លឹះនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់អនុវត្តក្របខណ្ឌលទ្ធផល រួមមានដូចខាងក្រោម ÷

- ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល និងក្រុមការងារបច្ចេកទេសចម្រុះ នឹងពិនិត្យឡើងវិញ នូវក្របខណ្ឌលទ្ធផលរបស់ខ្លួន ដែលផ្សារភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្ររបស់វិស័យ និងត្រូវកែលម្អបន្ថែមទៀត ដោយផ្អែកលើសមិទ្ធផលកន្លងមក ។
- តាមសំណើជាក់ស្តែងរបស់ក្រុមការងារនីមួយៗ គ. ជ. នា/ ក. អ. ក នឹងផ្តល់ការគាំទ្របច្ចេកទេស សម្រាប់រៀបចំ ឬពង្រឹងក្របខណ្ឌលទ្ធផល ។
- បង្កើនការយកចិត្តទុកដាក់លើគោលដៅ ដែលក្រុមការងារបច្ចេកទេសចម្រុះត្រូវអនុវត្តឱ្យបានសម្រេច តាមរយៈការត្រួតពិនិត្យប្រចាំឆ្នាំ និងការផ្សារភ្ជាប់គោលដៅទាំងនេះ ជាមួយសូចនាករតាមដានរួមគ្នា ។
- បញ្ចូលតម្រូវការក្នុងការអភិវឌ្ឍសមត្ថភាព និងប្រព័ន្ធជាតិ រួមទាំងភាពជាដៃគូ ទៅក្នុងក្របខណ្ឌលទ្ធផល ។

*៣- <u>សូចនាករតាមដានរួមគ្នា</u>*

ក្នុងឆ្នាំ ២០១២ សូចនាករតាមដានរួមគ្នា ត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការអនុវត្តអភិក្រមដោយផ្តោតលើលទ្ធផល ។ សូចនាករទាំងនេះបានក្លាយជាឧបករណ៍ សម្រាប់កំណត់គោលដៅរួម និងសម្រាប់តាមដានវឌ្ឍនភាពរួមគ្នា ក្នុងការអនុវត្តគោលដៅទាំងនេះ និងសម្រាប់រៀបចំរបៀបវារៈនៃកិច្ចពិគ្រោះយោបល់ ។ ក្នុងន័យនេះ សូចនាករតាមដានរួមគ្នា នៅតែជាឧបករណ៍សំខាន់ សម្រាប់គាំទ្រដល់ការអនុវត្តន៍យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ។

សូចនាករតាមដានរួមគ្នាតាមវិស័យ ត្រូវរៀបចំនាដើមឆ្នាំ ២០១៤ សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ស្របតាមអាណត្តិកាលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) ។ ប៉ុន្តែ ការពិនិត្យវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ត្រូវប្រព្រឹត្តទៅ ជារៀងរាល់ឆ្នាំ ហើយវឌ្ឍនភាពនេះត្រូវរាយការណ៍ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីឯកភាពលើសកម្មភាពប្រចាំឆ្នាំដែលត្រូវអនុវត្ត សំដៅធានាសម្រេចឱ្យបាន នូវគោលដៅដែលបានកំណត់ ។ សូចនាករតាមដានរួមគ្នាត្រូវបង្កើតឡើង ដោយផ្អែកលើក្របខណ្ឌលទ្ធផលដែលមានស្រាប់នៅតាមវិស័យ (ឬ បញ្ចូលទៅក្នុងក្របខណ្ឌលទ្ធផលនៅកម្រិតវិស័យ ដែលនឹងត្រូវរៀបចំ នាពេលអនាគត) ។ ទន្ទឹមនឹងនេះ សូចនាករតាមដានរួមគ្នាទាំងនេះ ក៏ត្រូវរំលេចនៅក្នុងបណ្ដាសកម្មភាពអាទិភាព ដែលត្រូវត្រួតពិនិត្យក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផងដែរ ។ អនុវត្តបែបនេះ ទើបអាចធានាបាននូវសង្គតិភាព រវាងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកិច្ចការដែលត្រូវអនុវត្តនៅកម្រិតវិស័យ ។

ក្នុងយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សកម្មភាពគន្លឹះដែលពាក់ព័ន្ធនឹងសូចនាករតាមដានរួមគ្នា រួមមាន ÷

- ក្រសួង និងស្ថាប័ន និងក្រុមការងារបច្ចេកទេសចម្រុះ ត្រូវកំណត់គោលដៅ (លទ្ធផល) និងសូចនាករតាមដាន សម្រាប់រយៈពេល ៥ ឆ្នាំ ២០១៤-២០១៨ ។
- ក្រសួង និងស្ថាប័ន និងក្រុមការងារបច្ចេកទេសចម្រុះ ត្រូវរៀបចំសកម្មភាពប្រចាំឆ្នាំ សម្រាប់អនុវត្ត ក្នុងគោលដៅធានាវឌ្ឍនភាព ដើម្បីឈានទៅសម្រេចលទ្ធផល តាមរយៈការកំណត់ធាតុចេញសំខាន់ៗ ទន្ទឹមនឹងផ្ដោតការយកចិត្តទុកដាក់ ទៅលើតម្រូវការនៃការពង្រឹងសមត្ថភាព និងប្រព័ន្ធជាតិ ។
- ការត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ជាផ្នែកមួយនៃកម្មវិធីការងារ របស់ក្រុមការងារបច្ចេកទេសចម្រុះ ។
- ដៃគូអភិវឌ្ឍន៍ដែលកំពុងប្រតិបត្តិការតាមវិស័យ ត្រូវពិនិត្យក្របខណ្ឌលទ្ធផលរបស់គម្រោងខ្លួនឡើងវិញ ដើម្បីធានាឱ្យមានសង្គតិភាពជាមួយអាទិភាពរបស់វិស័យ ឬ ក្រុមការងារបច្ចេកទេសចម្រុះ រួមទាំងការអភិវឌ្ឍសមត្ថភាព និងការពង្រឹងប្រព័ន្ធជាតិ ។

### *<u>៤-ការលើកកម្ពស់តម្លាភាព គណនេយ្យភាព និងលទ្ធផលក្នុងការប្រើប្រាស់ធនធាន</u>*

រាជរដ្ឋាភិបាលបានប្ដេជ្ញាលើកកម្ពស់គុណភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងប្រើប្រាស់ឧបករណ៍គ្រប់គ្រងព័ត៌មាន ដើម្បីពង្រឹងការសម្របសម្រួល ការរៀបចំផែនការ និងថវិកា ការអនុវត្ត និងការធ្វើរបាយការណ៍ ព្រមទាំងការត្រួតពិនិត្យ សម្រាប់លើកកម្ពស់ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលក៏បានផ្ដល់ការយកចិត្តទុកដាក់ខ្ពស់ ដល់ការលើកកម្ពស់តម្លាភាពធនធាន និងការសម្របសម្រួលក្នុងការអនុវត្តសកម្មភាពនានា ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងបន្តប្រើប្រាស់ឧបករណ៍ចំនួន ២ គឺ ÷ (១) ប្រព័ន្ធទិន្នន័យស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលគ្រប់គ្រងដោយ គ.ជ.ន.ទ/ក.អ.ក និង (២) ក្របខណ្ឌណែនាំស្ដីពីហិរញ្ញប្បទាន

សហប្រតិបត្តិការពហុឆ្នាំ ដែលត្រូវបានប្រើប្រាស់ប្រកបដោយជោគជ័យ ក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដើម្បីប៉ាន់ប្រមាណអំពីទំហំហិរញ្ញប្បទានរយៈពេលមធ្យមរបស់ដៃគូអភិវឌ្ឍន៍ ។

ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានបង្កើតឡើង នាឆ្នាំ ២០០៥ បានកត់ត្រា និងបានចែករំលែកព័ត៌មានស្តីពីសកម្មភាពគាំទ្រនានារបស់ដៃគូអភិវឌ្ឍន៍ ។ ក្នុងឆ្នាំ ២០០៨ ប្រព័ន្ធទិន្នន័យមួយទៀតត្រូវបានបង្កើត សម្រាប់កត់ត្រាព័ត៌មានស្តីពីសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ប្រព័ន្ធទិន្នន័យទាំង ២ នេះ ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ សម្រាប់សម្រួលដល់ការរៀបចំផែនការ និងថវិកា ព្រមទាំងជួយសម្របសម្រួលសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ។ ទន្ទឹមនឹងនេះ ការផ្សព្វផ្សាយជាសាធារណៈ នូវប្រព័ន្ធទិន្នន័យទាំងនេះ បានផ្តល់លទ្ធភាពដល់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងដៃគូអភិវឌ្ឍន៍ ទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានទាំងនោះ ។ ដោយកម្ពុជាបានផ្ទេរការយកចិត្តទុកដាក់ ពីភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ ទៅភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានកែលម្អប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីកត់ត្រាព័ត៌មានផ្នែកខាងគុណភាព សម្រាប់កម្ពុជាចូលរួមក្នុងការធ្វើអង្កេតកម្រិតសកល ឆ្នាំ ២០១៣ ស្តីពីការតាមដានការអនុវត្តការប្តេជ្ញានានាក្នុងវេទិកាកំពូល នៅទីក្រុងប៊ូសាន ។ លើសពីនេះ ឧបករណ៍មួយចំនួន ក៏ត្រូវបានបង្កើតក្នុងប្រព័ន្ធទិន្នន័យ សម្រាប់កត់ត្រាព័ត៌មានបន្ថែមមួយចំនួនរបស់គម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន កិច្ចសហប្រតិបត្តិការត្បូង– ត្បូង និងអង្គការសង្គមស៊ីវិល ព្រមទាំងការងារអន្តរវិស័យដែលមានសារៈសំខាន់ ក្នុងការលើកកម្ពស់ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ដូចជាការបញ្រ្ជាបយេនឌ័រ បម្រែបម្រួលអាកាសធាតុ និងការអភិវឌ្ឍយុវជន ជាដើម ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលអាចប្រើប្រាស់ប្រព័ន្ធទិន្នន័យទាំងនេះ សម្រាប់តាមដាន និងវាយតម្លៃ ខាងបរិមាណ និងគុណភាព ទាំងនៅថ្នាក់ជាតិ ទាំងនៅកម្រិតវិស័យ ។

រាជរដ្ឋាភិបាលបានប្រើប្រាស់ក្របខណ្ឌណែនាំស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការពហុឆ្នាំ ចាប់ពីឆ្នាំ ២០០៧ ចំនួន ៣ លើក នៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា សម្រាប់ប្រមូលព័ត៌មានស្តីពីទំហំហិរញ្ញប្បទានដែលដៃគូអភិវឌ្ឍន៍គ្រោងផ្តល់ឱ្យកម្ពុជា ដើម្បីគាំទ្ររាជរដ្ឋាភិបាលក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ តួលេខទាំងនេះ បានបញ្ជាក់អំពីការប៉ាន់ស្មានទំហំហិរញ្ញប្បទាន ហើយមិនមែនជាការប្តេជ្ញាផ្តល់ហិរញ្ញប្បទានឡើយ ។ ដោយអនុវត្តតាមការប្តេជ្ញានៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ទីក្រុងអាក្រា និងទីក្រុងប៊ូសាន ដៃគូអភិវឌ្ឍន៍បានផ្តល់តួលេខប៉ាន់ស្មាន សម្រាប់រយៈពេលមធ្យម ។ នាអនាគត ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ នឹងត្រូវប្រើប្រាស់ សម្រាប់រៀបចំក្របខណ្ឌណែនាំស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការពហុឆ្នាំ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីដៃគូអភិវឌ្ឍន៍ផ្តល់តួលេខប៉ាន់ស្មានអំពីធនធានរបស់ខ្លួនសម្រាប់រយៈពេលខាងមុខ ។

រាជរដ្ឋាភិបាលនឹងបន្តប្រើប្រាស់ឧបករណ៍ដូចបានរៀបរាប់ខាងលើ សម្រាប់រៀបចំឯកសារវិភាគសំខាន់ ដូចជារបាយការណ៍ស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ និងបន្តផ្សព្វផ្សាយព័ត៌មានជាសាធារណៈ នូវឯកសារដែលពាក់ព័ន្ធនឹងកិច្ចប្រជុំនៃវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា និងនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូ

អភិវឌ្ឍន៍ តាមរយៈគេហទំព័ររបស់ គ.ជ.ទា/ក.អ.ក ក៏ដូចជាក្របខណ្ឌណែនាំស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការពហុឆ្នាំ សម្រាប់ពង្រឹងគុណភាពនៃការគ្រប់គ្រងកម្មវិធីសហប្រតិបត្តិការ និងលើកកម្ពស់តម្លាភាព និងភាពអាចទស្សន៍ទាយជាមុន នូវធនធានរបស់ដៃគូអភិវឌ្ឍន៍ ។

សរុបមក ឧបករណ៍ទាំង ៤ មានគោលដៅដើម្បីដោះស្រាយបញ្ហាប្រឈម និងកាលានុវត្តភាព ដែលបានលើកឡើងក្នុងយុទ្ធសាស្ត្រនេះ ។ ទន្ទឹមនឹងនេះ ក៏ឆ្លុះបញ្ចាំងអំពីទំនាក់ទំនង រវាងការអនុវត្តឧបករណ៍ទាំងនេះ ជាមួយគោលដៅ និងទិសដៅស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ តួនាទីរបស់ឧបករណ៍នីមួយៗ ត្រូវបានសង្ខេបក្នុងតារាងខាងក្រោម :

| ***ការផ្សារភ្ជាប់គ្នារវាងកម្រិតទាំង ៣ : កម្រិតគម្រោង- កម្រិតវិស័យ- កម្រិតជាតិ ក្នុងការរៀបចំកម្មវិធី និងការតាមដាន*** | | |
|---|---|---|
| ***កម្រិតជាតិ : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** | ***កម្រិតវិស័យ : យុទ្ធសាស្ត្រ និង ផែនការតាមវិស័យ*** | ***កម្រិតគម្រោង*** |
| ***ការប្រើប្រាស់ក្របខណ្ឌលទ្ធផល សម្រាប់ផ្សារភ្ជាប់ រវាងកម្រិតជាតិ កម្រិតវិស័យ និងកម្រិតគម្រោង និងការតាមដាន តាមរយៈក្របខណ្ឌលទ្ធផល នៅកម្រិតជាតិ និងកម្រិតវិស័យ*** | | |
| - សូចនាករតាមដានរួមគ្នា ផ្សារភ្ជាប់នឹងសូចនាករនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>- ការតាមដានវឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ វេទិកាអភិវឌ្ឍន៍កម្ពុជា និងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានផ្តល់កាលានុវត្តភាព សម្រាប់ពិភាក្សាអំពីលទ្ធផលដែលសម្រេចបាន (ធាតុចេញ លទ្ធផល និងផលប្រយោជន៍សម្រាប់រយៈពេលវែង) | - ការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ជំរុញការតម្រឹម ការធ្វើសុខដុមនីយកម្ម និងការពង្រឹងប្រព័ន្ធជាតិ<br>- ក្របខណ្ឌលទ្ធផលតាមវិស័យ និង សូចនាករតាមដានរួមគ្នា ផ្សារភ្ជាប់ទៅនឹងក្របខណ្ឌលទ្ធផលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រថវិកា | - ប្រព័ន្ធព័ត៌មានស្តីពីហិរញ្ញប្បទានសហ-ប្រតិបត្តិការ កត់ត្រាទំហំហិរញ្ញប្បទានដែលបានបើកផ្តល់ និងដែលគ្រោងផ្តល់ គឺជាឧបករណ៍សម្រាប់តាមដានវឌ្ឍនភាពក្នុងការអនុវត្តសូចនាករកម្រិតជាតិ និងសូចនាករកម្រិតសកល<br>- ក្របខណ្ឌលទ្ធផលនៃគម្រោងនីមួយៗ ត្រូវតម្រឹមជាមួយគោលដៅរបស់វិស័យ |

## គ- <u>ភាពជាដៃគូសម្រាប់គាំទ្រភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍</u>

ទន្ទឹមនឹងការបន្តពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងការទទួលស្គាល់អំពីតួនាទីរបស់តួអង្គអភិវឌ្ឍន៍ទាំងអស់ ទិសដៅសំខាន់មួយនៃយុទ្ធសាស្ត្រនេះ គឺការបង្កើនកាលានុវត្តភាព សម្រាប់បង្កើនការចូលរួមកាន់តែខ្លាំងក្លាជាងមុន របស់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងដៃគូក្នុងក្របខណ្ឌនៃ**កិច្ចសហប្រតិបត្តិការត្បូង-ត្បូង** ក៏ដូចជាពង្រឹងកិច្ចសម្របសម្រួលធនធាន ដែលតួអង្គនីមួយៗ បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។

### *១- <u>ការជំរុញការអភិវឌ្ឍវិស័យឯកជន</u>*

វិស័យឯកជនបានចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលជាងមួយទស្សវត្សរ៍កន្លងមក ។ ទន្ទឹមនឹងការជួយជំរុញកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជន ទាំងក្នុងប្រទេស និងពីក្រៅប្រទេស បានជួយបង្កើតការងារ លើកកម្ពស់គុណភាពសេវាសាធារណៈ និងកែលម្អជីវភាពរបស់ប្រជាជន ព្រមទាំងបង្កើនចំណូលពន្ធ ។ លើមូលដ្ឋាននេះ ការបន្តពង្រឹងភាពជាដៃគូរវាងដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន នឹងផ្តល់សក្តានុពលបន្ថែមទៀត សម្រាប់បន្តជំរុញកំណើនសេដ្ឋកិច្ចផង និងផ្តល់អត្ថប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាផង ។

ក្នុងស្មារតីនេះ ដៃគូអភិវឌ្ឍន៍អាចផ្តល់ការគាំទ្រក្នុងកិច្ចការសំខាន់ៗ ៤ ដូចខាងក្រោម សម្រាប់សម្រួលកិច្ចអភិវឌ្ឍន៍របស់វិស័យឯកជន ÷

- ពង្រឹងបរិស្ថានអំណោយផលសម្រាប់អភិវឌ្ឍវិស័យឯកជន ។
- លើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ចរបស់កម្ពុជា ។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ រួមទាំងការពង្រឹង**ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន** ។
- បង្កើតភាពជាដៃគូផ្ទាល់ជាមួយផ្នែកឯកជន តាមរយៈការផ្តល់ការគាំទ្រក្នុងការផ្តល់សេវាសាធារណៈ ឬការកែលម្អបរិស្ថានធុរកិច្ច ។

*២- <u>ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព</u>*

រាជរដ្ឋាភិបាលទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល ទាំងខាងធនធាន ទាំងខាងការផ្តល់សេវាក្នុងវិស័យសង្គមកិច្ច ពិសេស ក្នុងវិស័យសុខាភិបាល អប់រំ ការអភិវឌ្ឍជនបទ សុខុមាលភាពសហគមន៍ និងការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ។ បន្ថែមលើធនធានផ្ទាល់ខ្លួន អង្គការមិនមែនរដ្ឋាភិបាលក៏ជាភ្នាក់ងារគ្រប់គ្រង និងអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍ផងដែរ ។ ទន្ទឹមនឹងនេះ អង្គការមិនមែនរដ្ឋាភិបាល បានចូលរួមក្នុងកិច្ចប្រតិបត្តិការសង្គ្រោះបន្ទាន់ ដែលដឹកនាំដោយរាជរដ្ឋាភិបាល ទាំងនៅក្នុងពេលមានគ្រោះទឹកជំនន់ ក៏ដូចជានៅក្រោយពេលគ្រោះទឹកជំនន់ ។ លើសពីនេះ កិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល និងសហគមន៍អង្គការមិនមែនរដ្ឋាភិបាល នៅក្រោយពេលគ្រោះទឹកជំនន់ បានរំលេចឱ្យឃើញអំពីកិច្ចការ និងផ្នែកជាច្រើន ដែលអាចបន្តពង្រឹងកិច្ចសហការ ។ ជាមួយគ្នានេះ កិច្ចប្រឹងប្រែងផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ពង្រឹងកិច្ចសម្របសម្រួលផ្ទៃក្នុងរបស់ខ្លួន និងបង្កើនតម្លាភាពក្នុងការប្រើប្រាស់ធនធាន ព្រមទាំងពង្រឹងកិច្ចសហការជាមួយរាជរដ្ឋាភិបាល គឺជាកត្តាសំខាន់ ក្នុងការពង្រឹងទំនាក់ទំនងរវាងភាគីពាក់ព័ន្ធទាំងអស់ នាពេលអនាគត ។

*៣- <u>កិច្ចសហប្រតិបត្តិការត្បូង- ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ</u>*

**កិច្ចសហប្រតិបត្តិការត្បូង- ត្បូង** និង **កិច្ចសហប្រតិបត្តិការត្រីកោណ** គឺជាទម្រង់សហប្រតិបត្តិការ សម្រាប់បំពេញបន្ថែមឱ្យ**កិច្ចសហប្រតិបត្តិការជើង- ត្បូង** ដែលធ្លាប់បានអនុវត្តកន្លងមក ។ ទម្រង់សហប្រតិបត្តិការទាំង ២ នេះ អាចផ្តល់ដំណោះស្រាយ ទាំងកម្រិតគោលនយោបាយ ទាំងកម្រិតបច្ចេកទេស និងមានភាពទន់ភ្លន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព និងចីរភាព ស្របតាមបរិការណ៍របស់ប្រទេសនីមួយៗ ។ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ បានរំលេចអំពីគោលការណ៍សំខាន់ៗ ដូចខាងក្រោម សម្រាប់បង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ទម្រង់កិច្ចសហប្រតិបត្តិការទាំង ២ នេះ ÷

- ធានាភាពជាម្ចាស់ និងការតម្រឹម ដោយប្រើប្រាស់គោលនយោបាយ យន្តការរៀបចំផែនការ និងត្រួតពិនិត្យដែលមានស្រាប់ រួមទាំងយន្តការភាពជាដៃគូដែលមានបច្ចុប្បន្ន សម្រាប់កំណត់សក្តានុពលនៃការប្រើប្រាស់ទម្រង់កិច្ចសហប្រតិបត្តិការត្បូង- ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ ។

- បង្កើនប្រសិទ្ធភាព និងលទ្ធផលនៃការអនុវត្តទម្រង់ទាំង ២ នេះ តាមរយៈការបង្កើនប្រសិទ្ធភាពក្នុងកម្មវិធីនីយកម្ម និងការអនុវត្ត ដោយផ្សារភ្ជាប់នឹងក្របខណ្ឌលទ្ធផល និងក្របខណ្ឌតាមដានរបស់វិស័យ ។
- ទម្រង់កិច្ចសហប្រតិបត្តិការទាំងនេះ ត្រូវអនុវត្តតាមគោលការណ៍នៃទម្រង់ដទៃទៀត ដើម្បីជំរុញការតម្រឹមធនធានជាមួយនឹងអាទិភាព និងលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ ទម្រង់សហប្រតិបត្តិការទាំង ២ នេះ នឹងក្លាយជារបៀបវារៈ សម្រាប់ពិភាក្សាកម្រិតគោលនយោបាយនៅតាមវិស័យ ជាមួយនឹងភាគីពាក់ព័ន្ធ ។
- បង្កើនប្រសិទ្ធភាពនៃទម្រង់កិច្ចសហប្រតិបត្តិការទាំង ២ នេះ តាមរយៈការបង្កើតយន្តការសម្រាប់គ្រប់គ្រងពុទ្ធិ ដើម្បីកត់ត្រា និងផ្សព្វផ្សាយលទ្ធផល ព្រមទាំងពង្រីកវិសាលភាពនៃការអនុវត្តទម្រង់កិច្ចសហប្រតិបត្តិការទាំងនេះ ។
- កំណត់ និងបង្កើនការប្រើប្រាស់ទម្រង់កិច្ចសហប្រតិបត្តិការ តាមរយៈការបង្កើតដំណើរការ ដើម្បីកំណត់អំពីតម្រូវការ និងការស្វែងរកដៃគូសម្រាប់គាំទ្រ ។

ទន្ទឹមនឹងគោលការណ៍សំខាន់ៗ ឧបករណ៍ និងភាពជាដៃគូ ដូចបានរំលេចក្នុងយុទ្ធសាស្ត្រនេះ កិច្ចប្រឹងប្រែងក៏ត្រូវបន្តផ្តោតការយកចិត្តទុកដាក់ ទៅលើការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចពិភាក្សា តាមរយៈការប្រើប្រាស់យន្តការភាពជាដៃគូ ។

## ៥- យន្តការពិគ្រោះយោបល់ និងភាពជាដៃគូ

យន្តការពិគ្រោះយោបល់បានដើរតួនាទីស្នូល ក្នុងការគ្រប់គ្រង និងការបង្កើនភាពស័ក្តិសិទ្ធិនៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ។ ក្នុងពេលរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ រាជរដ្ឋាភិបាលបានពិនិត្យឡើងវិញ នូវយន្តការពិគ្រោះយោបល់ទាំងឡាយដែលបានបង្កើតឡើង និងកំពុងដាក់ឱ្យដំណើរការ ដើម្បីធានាភាពត្រឹមត្រូវ និងលើកកម្ពស់ប្រសិទ្ធភាព ។ ផ្អែកលើសារៈសំខាន់នៃការបន្តពង្រឹង និងអនុវត្តយន្តការទាំងនេះ រាជរដ្ឋាភិបាលសម្រេចរក្សាទុករចនាសម្ព័ន្ធយន្តការពិគ្រោះយោបល់ទាំង ៣ កម្រិត ដែលធ្លាប់អនុវត្តកន្លងមក ទន្ទឹមនឹងការកែសម្រួលសមាសធាតុសំខាន់ៗមួយចំនួន ដោយផ្អែកលើបទពិសោធន៍ និងការពិភាក្សាជាមួយភាគីពាក់ព័ន្ធ ។ លើសពីនេះ យន្តការពិគ្រោះយោបល់ នឹងបំពេញបន្ថែមដោយយន្តការពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ ។ តារាងសង្ខេបនៃយន្តការពិគ្រោះយោបល់ មានបង្ហាញក្នុងទំព័របន្ទាប់ ។

ការផ្តល់សារៈសំខាន់កាន់តែខ្លាំងឡើង ទៅលើអភិក្រមដោយផ្តោតលើលទ្ធផល និងអភិក្រមស្តីពីភាពជាដៃគូក្នុងកិច្ចពិគ្រោះយោបល់ស្តីពីកិច្ចអភិវឌ្ឍន៍កម្ពុជា បានបង្ហាញអំពីតម្រូវការនៃការប្រើប្រាស់មុខជំនាញដែលពាក់ព័ន្ធនឹងភាពជាដៃគូ ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចពិគ្រោះយោបល់ ។ រាជរដ្ឋាភិបាលទទួលស្គាល់ពីសារៈប្រយោជន៍ ក្នុងការពង្រឹងភាពទុកចិត្តគ្នា តម្លាភាព និងអត្ថប្រយោជន៍ទ្វេទិស ដើម្បីលើកកម្ពស់គុណភាព និងលទ្ធផលនៃកិច្ចពិគ្រោះយោបល់ ។ នេះមានន័យថា តាមរយៈការអនុវត្តឧបករណ៍ដូចបានលើកឡើងក្នុងផ្នែកទី ៤ ខាងដើម ភាគីទាំងអស់ត្រូវបានលើកទឹកចិត្ត និងត្រូវមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលរួមពិភាក្សាប្រកបដោយប្រសិទ្ធភាព នៅក្នុងយន្តការពិគ្រោះយោបល់ទាំងនេះ រួមទាំងការអនុវត្តសកម្មភាពអាទិភាពនានា និងការត្រួតពិនិត្យវឌ្ឍនភាព ព្រមទាំងការដកស្រង់បទពិសោធន៍រួមគ្នា ក្នុងការអនុវត្ត ។ យន្តការពិគ្រោះយោបល់ទាំង ៣ កម្រិតនេះ មានដូចខាងក្រោម ÷

## ក- <u>វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (វេទិកាអភិវឌ្ឍន៍កម្ពុជា)</u>

វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នឹងវិវត្តន៍ឈានឡើង ទៅជាវេទិកាអភិវឌ្ឍន៍កម្ពុជា ដោយមានការចូលរួមកាន់តែច្រើនឡើង របស់តួអង្គអភិវឌ្ឍន៍ ដូចជា វិស័យឯកជន និងសង្គមស៊ីវិល ។ វេទិកាអភិវឌ្ឍន៍កម្ពុជានឹងផ្តោតការយកចិត្តទុកដាក់លើការងារនានា ដែលពាក់ព័ន្ធនឹងភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ និងបញ្ហាហិរញ្ញប្បទាន ។ គោលដៅនៃវេទិកាអភិវឌ្ឍន៍កម្ពុជា គឺការផ្តល់កាលានុវត្តភាពឱ្យតួអង្គអភិវឌ្ឍន៍ទាំងអស់ ពិនិត្យ និងពិភាក្សារួមគ្នា អំពីវឌ្ឍនភាពនៃកិច្ចអភិវឌ្ឍន៍ និងបញ្ហាប្រឈមនានា សម្រាប់កំណត់យុទ្ធសាស្ត្រ និងសកម្មភាពសមស្រប ដែលត្រូវអនុវត្តរួមគ្នា ឬ ដែលត្រូវអនុវត្តដោយតួអង្គនីមួយៗ ។

<table>
<tr><td rowspan="1">កិច្ចពិគ្រោះយោបល់កម្រិតខ្ពស់</td><td colspan="4"><u>វេទិកាអភិវឌ្ឍន៍កម្ពុជា</u><br>- ជួបប្រជុំរៀងរាល់ ២ ឆ្នាំម្តង ដោយមានរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមក្នុងវេទិកានេះ<br>- កិច្ចប្រជុំកម្រិតកំពូល ស្តីពីការអភិវឌ្ឍន៍ជាតិ : អាទិភាព វឌ្ឍនភាព បញ្ហាប្រឈម ការផ្តល់ហិរញ្ញប្បទាន<br>- ផ្តល់អនុសាសន៍សម្រាប់កិច្ចពិគ្រោះយោបល់នៅថ្នាក់ក្រោម</td></tr>
<tr><td>កិច្ចពិគ្រោះយោបល់កម្រិតគោលនយោបាយ និងការតាមដានក្នុងការអនុវត្តគោលនយោបាយ</td><td>វេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន<br>- រៀបចំរៀងរាល់ឆ្នាំ ដោយផ្តោតលើ :<br>. ផ្តល់ជម្រើស និងអនុសាសន៍គោលនយោបាយនានា<br>. ការដោះស្រាយឧបសគ្គ និងកង្វល់នានា ក្នុងធុរៈកិច្ច</td><td>គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍<br>- រៀបចំរៀងរាល់ឆ្នាំ ដោយផ្តោតលើ :<br>. វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>. សូចនាករតាមដានរួមគ្នា<br>. កំណែទម្រង់វិស័យសាធារណៈ<br>. បញ្ហាអន្តរវិស័យ</td><td>កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល<br>- រៀបចំរៀងរាល់ឆ្នាំ ដោយផ្តោតលើ :<br>. តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់សេវាសាធារណៈ<br>. ភាពជាដៃគូសម្រាប់លើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ពិភាក្សាទូទៅ និងពិភាក្សា លើវិស័យជាក់លាក់</td><td rowspan="2">កិច្ចពិគ្រោះយោបល់ទ្វេភាគី រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍<br>- បន្តយន្តការដូចធ្លាប់អនុវត្តកន្លងមកក្រោមកិច្ចសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- កិច្ចប្រជុំទ្វេភាគី សម្រាប់ពិនិត្យការអនុវត្តកម្មវិធីសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ដើម្បីបំពេញបន្ថែមឱ្យយន្តការពិគ្រោះយោបល់ពហុភាគី និងជំរុញឱ្យដៃគូអភិវឌ្ឍន៍តម្រឹមការគាំទ្ររបស់ខ្លួន ស្របតាមអាទិភាពដែលបានកំណត់ក្នុង «ក្របខណ្ឌលទ្ធផល» ។</td></tr>
<tr><td>ការពិភាក្សាកម្រិតបច្ចេកទេស និងការចែករំលែកព័ត៌មាន</td><td>- ក្រុមការងារ៩ សម្រាប់សម្របសម្រួលផ្នែកឯកជន<br>- ដៃគូអភិវឌ្ឍន៍សម្របសម្រួលតាមរយៈ<br>. គណៈកម្មាធិការដឹកនាំការងារសម្រាប់អភិវឌ្ឍវិស័យឯកជន<br>. ក.អ.ក ជាលេខាធិការដ្ឋាននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន<br>. សភាពាណិជ្ជកម្មកម្ពុជា</td><td>ក្រុមការងារបច្ចេកទេសចម្រុះ<br>- ក្រុមការងារបច្ចេកទេសចម្រុះត្រូវពិនិត្យឡើងវិញ នូវតួនាទី និងទម្រង់នៃកិច្ចដំណើរការ<br>- ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំក្រៅផ្លូវការ<br>- សមាជិកនៃក្រុមការងារកំណត់តម្រូវការធនធាន និងប្រភពធនធានសម្រាប់គាំទ្រលេខាធិការដ្ឋាន ។</td><td>- អង្គការមិនមែនរដ្ឋាភិបាល ចូលរួមយ៉ាងសកម្មក្នុងក្រុមការងារបច្ចេកទេសចម្រុះ<br>- ភ្នាក់ងារតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល មានតួនាទីសម្របសម្រួល ជាមួយសហគមន៍អង្គការមិនមែនរដ្ឋាភិបាល មុនកិច្ចប្រជុំប្រចាំឆ្នាំ (ដូចជាកិច្ចប្រជុំត្រៀមនិងការរៀបចំរបៀបវារៈ ជាដើម)</td></tr>
</table>

ការផ្ទេរពីវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ទៅវេទិកាអភិវឌ្ឍន៍កម្ពុជា នឹងត្រូវដំណើរការជាជំហានៗ ។ វេទិកាអភិវឌ្ឍន៍កម្ពុជាលើកទី ១ នឹងត្រូវដំណើរការ ដោយរៀបចំឱ្យមានកិច្ចប្រជុំ ២ បណ្តាក់គ្នា គឺ : កិច្ចប្រជុំមួយ

ផ្តោតលើកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងមួយទៀត ផ្តោតលើការអភិវឌ្ឍវិស័យឯកជន ។ រាជរដ្ឋាភិបាលនឹងវាយតម្លៃ ដើម្បីឈានទៅធ្វើសមាហរណកម្មយន្តការទាំង ២ នេះ ។ វេទិកាអភិវឌ្ឍន៍កម្ពុជានឹងប្រជុំរៀងរាល់ ២ ឆ្នាំម្តង ។

**ខ- គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍**

គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺជាវេទិកាសំខាន់ សម្រាប់ពិនិត្យវឌ្ឍនភាព និងជាកិច្ចប្រជុំកម្រិតគោលនយោបាយ រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ។ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវប្រជុំប្រចាំឆ្នាំ និងមានរយៈពេលកន្លះថ្ងៃ ។ កិច្ចប្រជុំនេះត្រូវផ្តោតលើវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងអាទិភាពនៃកិច្ចអភិវឌ្ឍន៍ប្រទេស ជាអាទិ៍មាន កំណែទម្រង់ស្នូលក្នុងវិស័យសាធារណៈ និងបញ្ហាអន្តរវិស័យ ។ ក្នុងដំណាក់កាលឈានឡើង ឆ្ពោះទៅវេទិកាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នឹងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ទៅលើបញ្ហាភាពជាដៃគូដែលទាក់ទងនឹងហិរញ្ញប្បទានសហប្រតិបត្តិការ និងបញ្ហាដទៃទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនង និងកិច្ចដំណើរការការងាររវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ កិច្ចប្រជុំនេះក៏ពិនិត្យផងដែរ អំពីការរៀបចំ និងការអនុវត្តសូចនាករតាមដានរួមគ្នា និងការពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកំណែទម្រង់ក្នុងវិស័យសាធារណៈ ព្រមទាំងតួលេខប៉ាន់ស្មានផ្តល់ហិរញ្ញប្បទាន ក្នុងក្របខណ្ឌណែនាំស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការពហុឆ្នាំ ។ ប្រធាន និងលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះនឹងជួបប្រជុំរៀងរាល់ត្រីមាស ជាមួយប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងតំណាងសំខាន់របស់ដៃគូអភិវឌ្ឍន៍ ដើម្បីតាមដានវឌ្ឍនភាព ក្នុងការដោះស្រាយបញ្ហាប្រឈម ដែលបានលើកឡើងក្នុងកិច្ចប្រជុំ ឬ ដើម្បីកំណត់បញ្ហាប្រឈមដែលបានលេចឡើង ក្នុងចន្លោះពេលពីកិច្ចប្រជុំមួយ ទៅកិច្ចប្រជុំមួយទៀត ព្រមទាំងរួមគ្នារៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំបន្ទាប់ ។

**គ- ក្រុមការងារបច្ចេកទេសចម្រុះ**

ក្រុមការងារបច្ចេកទេសចម្រុះ ដែលជាមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធភាពជាដៃគូ មានតួនាទីសម្របសម្រួលកិច្ចពិភាក្សាបច្ចេកទេស ក្នុងកម្រិតវិស័យ និងអន្តរវិស័យ ព្រមទាំងកម្មវិធីកែទម្រង់នានា សម្រាប់គាំទ្រដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ការតាមដាន និងការដកស្រង់បទពិសោធន៍ ។ «ឯកសារណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ» នៅតែមានភាពសមស្របនឹងបរិការណ៍កម្ពុជា ។ ក្នុងស្មារតីនេះ នៅពេលចាប់ផ្តើមការងាររបស់ខ្លួន នាឆ្នាំ២០១៤ សម្រាប់បន្តអនុវត្តភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវពិនិត្យឡើងវិញ នូវរបៀបរបបធ្វើការងាររបស់ខ្លួន រួមទាំងពិនិត្យអំពីសមាជិកភាព និងតម្រូវការគាំទ្ររបស់លេខាធិការដ្ឋាន ដើម្បីអនុវត្តអភិក្រមផ្តោតលើលទ្ធផល និងធានាភាពត្រឹមត្រូវនៃលក្ខខណ្ឌយោងរបស់ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ។ ក្នុងបរិការណ៍នៃភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវបន្តការយកចិត្តទុកដាក់ខ្ពស់ លើបញ្ហាអន្តរវិស័យ ដូចជាយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ក៏ដូចជាការបន្តពង្រឹងសមត្ថភាព និងប្រព័ន្ធជាតិ ដើម្បីធានាសង្គតិភាពជាមួយការដ្ឋានកែទម្រង់វិស័យសាធារណៈរបស់រាជរដ្ឋាភិបាល ។ ក្រុមការងារបច្ចេកទេសចម្រុះ អាចរៀបចំកិច្ចប្រជុំក្រៅផ្លូវការ ឬ រៀបចំកិច្ចប្រជុំនៃក្រុមសមាជិកស្នូល ដើម្បីពិភាក្សា

ពីបញ្ហាគន្លឹះនានា មុនកិច្ចប្រជុំផ្លូវការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ឬ របស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យក្រុមការងារបច្ចេកទេសចម្រុះ អនុវត្តអភិក្រមរួមគ្នា ក្នុងការរៀបចំផែនការ និងកម្មវិធី ព្រមទាំងការពិនិត្យវឌ្ឍនភាព តាមរយៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ ក្របខណ្ឌលទ្ធផលដែលផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រ ឬ ផែនការតាមវិស័យ គឺជាមូលដ្ឋានគ្រឹះ សម្រាប់រៀបចំសូចនាករតាមដានរួមគ្នា និងជាក្របខណ្ឌសម្រាប់តាមដាន ។ ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ដើម្បីពិនិត្យវឌ្ឍនភាពការងារដោយផ្អែកលើក្របខណ្ឌលទ្ធផលរបស់វិស័យខ្លួន ហើយត្រូវរាយការណ៍ជូនកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ គ.ជ.ន/ក.អ.ក អាចផ្តល់ការគាំទ្របច្ចេកទេស ដល់ក្រុមការងារនីមួយៗតាមសំណើរបស់ប្រធានក្រុមការងារ ។

### ឃ- កិច្ចពិគ្រោះយោបល់ទ្វេភាគី

កិច្ចពិគ្រោះយោបល់ទ្វេភាគីមានសារប្រយោជន៍ សម្រាប់បំពេញបន្ថែមឱ្យយន្តការពិគ្រោះយោបល់ពហុភាគី ។ ជាទូទៅ កិច្ចពិគ្រោះយោបល់ទ្វេភាគី ដែលត្រូវបានរៀបចំ រៀងរាល់ឆ្នាំ ឬ រៀងរាល់ ២ ឆ្នាំម្តង ក្រោមការដឹកនាំរបស់ គ.ជ.ន/ក.អ.ក ឬ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់កាលានុវត្តភាព សម្រាប់ពិនិត្យវឌ្ឍនភាពការងារ ក៏ដូចជាពិភាក្សាស៊ីជម្រៅ លើបញ្ហាជាក់លាក់តាមវិស័យ ដែលពាក់ព័ន្ធនឹងកម្មវិធីសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ។ កន្លងមក ដៃគូអភិវឌ្ឍន៍មួយចំនួន មិនទាន់បានប្រើប្រាស់កាលានុវត្តភាពនេះ សម្រាប់រៀបចំកិច្ចប្រជុំទ្វេភាគីឡើយ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបន្តលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ រៀបចំកិច្ចប្រជុំទ្វេភាគី ជាមួយ គ.ជ.ន/ក.អ.ក (ចំពោះដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានឥតសំណង) និងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ចំពោះដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានជាកម្ចី) ដោយផ្តោតជាសំខាន់ លើការពិនិត្យវឌ្ឍនភាពការងារ ដើម្បីឈានទៅសម្រេចលទ្ធផល ដែលបានកំណត់ក្នុងកម្មវិធីសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ។ លើសពីនេះ ក៏ពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងបរិការណ៍របស់វិស័យ ដែលដៃគូអភិវឌ្ឍន៍បានគាំទ្រ និងការរួមចំណែករបស់ពួកគេ ក្នុងការអភិវឌ្ឍន៍សមត្ថភាព និងការពង្រឹងប្រព័ន្ធជាតិផងដែរ ។

### ង- កិច្ចពិគ្រោះយោបល់ជាមួយវិស័យឯកជន

**វេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន** គឺជាយន្តការសម្រាប់ពិភាក្សាស៊ីជម្រៅ លើបញ្ហានានាដែលពាក់ព័ន្ធនឹងបរិស្ថានធុរកិច្ច និងវិស័យឯកជន ។ កិច្ចពិភាក្សាក្នុងក្រុមការងារទាំង ៩ ចំណុះឱ្យយន្តការនេះ គឺជាមូលដ្ឋាន សម្រាប់រៀបចំរបៀបវារៈនៃវេទិកា ដែលរៀបចំជារៀងរាល់ឆ្នាំ ដោយមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអគ្គលេខាធិការដ្ឋាននៃវេទិកា ។ វេទិកានេះនឹងបន្តផ្តល់កាលានុវត្តភាពសំខាន់ សម្រាប់ផ្តល់ជម្រើស និងអនុសាសន៍កម្រិតគោលនយោបាយក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ទន្ទឹមនឹងការពិភាក្សា និងដោះស្រាយឧបសគ្គ និងកង្វល់នានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឯកជន ។

រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍវិស័យឯកជន តាមរយៈការពិភាក្សាជាមួយគណៈកម្មាធិការដឹកនាំការងារសម្រាប់អភិវឌ្ឍវិស័យឯកជន ។ លើសពីនេះ ការពិភាក្សាផ្ទាល់រវាងដៃគូអភិវឌ្ឍន៍ ជាមួយតំណាងវិស័យឯកជន រួមទាំងសភាពាណិជ្ជកម្មកម្ពុជា និងការគាំទ្រនានា សម្រាប់ពង្រឹងសមត្ថភាព មានគោលដៅបង្កើនប្រសិទ្ធភាពនៃការចូលរួមរបស់វិស័យនេះ នៅក្នុងវេទិកាអភិវឌ្ឍន៍កម្ពុជា និងការចូលរួមពិភាក្សា ក៏ដូចជាការផ្តល់យោបល់នានា ដែលពាក់ព័ន្ធនឹងទិសដៅ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ។

### ច- <u>កិច្ចពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល</u>

ផ្អែកលើលទ្ធផលដ៏ត្រចះត្រចង់នៃកិច្ចប្រជុំ កាលពីខែកុម្ភៈ ឆ្នាំ២០១២ បន្ទាប់ពីគ្រោះទឹកជំនន់ នាចុងឆ្នាំ ២០១១ រាជរដ្ឋាភិបាលបានសម្រេចឱ្យរៀបចំកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការដាក់ឱ្យអនុវត្ត នូវ **ឯកសារណែនាំស្តីពីកិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល** ដោយមាន គ.ជ.ន/ក.អ.ក ជាលេខាធិការដ្ឋាន ។ គោលដៅចម្បងនៃកិច្ចប្រជុំ គឺការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ក៏ដូចជានៅតាមវិស័យ និងអន្តរវិស័យ ព្រមទាំងកំណត់អំពីគោលដៅរួម និងសកម្មភាពសមស្រប សម្រាប់អនុវត្តរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល សម្រាប់លើកកម្ពស់ប្រសិទ្ធភាពការងារ ដើម្បីឈានទៅសម្រេចភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ។

លើមូលដ្ឋាននេះ កិច្ចពិគ្រោះយោបល់នឹងបង្កើនការយល់ដឹងរួម និងចែករំលែកព័ត៌មាន ស្តីពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងបង្កើតយន្តការតាមដាន ដើម្បីធានាអនុវត្តឱ្យសម្រេចបានលទ្ធផលខ្ពស់ ក្នុងកិច្ចអភិវឌ្ឍន៍ ។ អង្គការមិនមែនរដ្ឋាភិបាល ត្រូវជ្រើសរើសតំណាងសម្របសម្រួលរបស់ខ្លួន ដើម្បីសហការជាមួយរាជរដ្ឋាភិបាល សម្រាប់រៀបចំកិច្ចប្រជុំ និងតាមដានវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍នានា របស់អង្គប្រជុំ ។

## ៦- យន្តការស្ថាប័ន

ក្នុងគោលការណ៍ដឹកនាំ និងគ្រប់គ្រងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល នៅរក្សាតួនាទី ដូចមានចែងក្នុងក្របខណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០០៦ សម្រាប់រយៈពេលឆ្នាំ ២០០៦-២០១០ ។ គ.ជ.ន/ក.អ.ក ដែលជាស្ថាប័នសម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ បំពេញតួនាទីជាស្ថាប័នស្នូល ក្នុងកិច្ចការពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ តួនាទីរបស់ក្រសួង និងស្ថាប័ននីមួយៗ មានដូចខាងក្រោម ÷

ក- គ.ជ.ន/ក.អ.ក ដែលជាស្ថាប័នសម្របសម្រួល មានតួនាទីដឹកនាំក្នុងការរៀបចំគោលនយោបាយ ដែលពាក់ព័ន្ធនឹងការកៀរគរ និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ គ.ជ.ន/ក.អ.ក ជាស្ថាប័នស្នូល សម្រាប់ធ្វើការងារជាមួយដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានឥតសំណង ដើម្បីរៀបចំគម្រោង និងតាមដានការអនុវត្តគម្រោង ។ ក្នុងឋានៈជាលេខាធិការដ្ឋានសម្រាប់ពិនិត្យ និងសម្របសម្រួលយន្តការពិគ្រោះយោបល់ (វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា វេទិកាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការ

មិនមែនរដ្ឋាភិបាល និងក្រុមការងារបច្ចេកទេសចម្រុះ) គ.ជ.ទា/ក.អ.ក នឹងដឹកនាំកិច្ចពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ រៀបចំសូចនាករតាមដានរួមគ្នា និងតាមដានការអនុវត្តសូចនាករទាំងនេះ ព្រមទាំងកត់ត្រាព័ត៌មានដែលពាក់ព័ន្ធគម្រោងរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។ លើមូលដ្ឋាននេះ គ.ជ.ទា/ក.អ.ក អាចផ្តល់ការគាំទ្រដូចខាងក្រោម ÷

- រៀបចំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ឬ វេទិកាអភិវឌ្ឍន៍កម្ពុជា កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីសុខដុមនីយកម្ម និងភាពជាដៃគូ និងកិច្ចប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ។
- រៀបចំ និងតាមដានការអនុវត្តកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍របស់ដៃគូអភិវឌ្ឍន៍ ក្នុងក្របខណ្ឌហិរញ្ញប្បទានឥតសំណង ។
- វាយតម្លៃ និងផ្តល់ការយល់ព្រមលើគម្រោងឥតសំណង ក៏ដូចជាការចូលរួមវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគម្រោង ។
- គ្រប់គ្រងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល ។
- ផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ រួមទាំងការរៀបចំសូចនាករតាមដានរួមគ្នា និងការតាមដានការអនុវត្តសូចនាករទាំងនេះ ។
- សម្របសម្រួល និងផ្តល់ការគាំទ្រ តាមសំណើរបស់ក្រសួង និងស្ថាប័ន ។

ខ- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក) បំពេញតួនាទីជាអគ្គលេខាធិការដ្ឋាននៃវេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន និងសម្របសម្រួលការរៀបចំកិច្ចប្រជុំ ដោយសហការជាមួយក្រុមការងារទាំង៩ នៃវិស័យឯកជន ។

គ- ក្រសួងផែនការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះ សម្រាប់តម្រែតម្រង់ និងតម្រឹមការវិភាជន៍ហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយនឹងអាទិភាពជាតិ ។ លើសពីនេះ តាមរយៈកិច្ចសហការជាមួយ គ.ជ.ទា/ក.អ.ក និងក្រសួង និងស្ថាប័ន ក្រសួងផែនការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំ រំកិល ដើម្បីកំណត់គម្រោងអាទិភាព ដោយផ្អែកលើព័ត៌មានក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងធាតុចូលពីក្រសួង និងស្ថាប័ន ។

ឃ- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ។ ទន្ទឹមនឹងនេះ ផ្អែកលើធាតុចូលរបស់ គ.ជ.ទា/ក.អ.ក និងតម្រូវការហិរញ្ញប្បទានក្រៅប្រទេស ដែលមានចែងក្នុងកម្មវិធីវិនិយោគសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់អំពីតម្រូវការហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានកម្ចី សម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ ដោយត្រូវរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពនៃបំណុល ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាតំណាងឱ្យរាជរដ្ឋាភិបាល មានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានជាកម្ចី និងគ្រប់គ្រងការអនុវត្តគម្រោងហិរញ្ញប្បទានជាកម្ចី ចាប់ពីដំណាក់កាលនៃការរៀបចំ និងការវាយតំលៃគម្រោង រហូតដល់ការតាមដានការអនុវត្តគម្រោង ។ ជាគោលការណ៍ ហិរញ្ញប្បទានជា

កម្ចីត្រូវប្រើប្រាស់ សម្រាប់អនុវត្តគម្រោងដែលមានអត្រាសេដ្ឋកិច្ចខ្ពស់ ជាងចំណាយនៃការសងបំណុល ។ លើមូលដ្ឋាននេះ ហិរញ្ញប្បទានជាកម្ចីត្រូវប្រើប្រាស់ សម្រាប់គម្រោងសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ។ លើសពីនេះ រាជរដ្ឋាភិបាលអាចប្រើប្រាស់កម្ចី សម្រាប់គម្រោងក្នុងវិស័យសង្គម- សេដ្ឋកិច្ច ដែលអាចផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចផ្ទាល់សម្រាប់ប្រជាជន តាមរយៈការវិនិយោគសម្រាប់អភិវឌ្ឍមូលធនមនុស្ស និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។

ង- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបំពេញតួនាទីជាច្រកទ្វារការទូតក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ គ.ជ.នា/ក.អ.ក ទទួលខុសត្រូវរៀបចំកម្មវិធីសហប្រតិបត្តិការ និងចរចាគម្រោង ក្នុងក្របខណ្ឌហិរញ្ញប្បទានឥតសំណង ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រប់គ្រងហិរញ្ញប្បទានជាកម្ចី ។

ច- ក្រសួង និងស្ថាប័នពាក់ព័ន្ធ មានតួនាទីដឹកនាំក្រុមការងារបច្ចេកទេសចម្រុះ និងចាត់តាំងមន្ត្រីជាន់ខ្ពស់ឱ្យចូលរួមក្នុងក្រុមការងារទាំងនេះ ស្របតាមអាណត្តិកាលនៃស្ថាប័នខ្លួន ។ ក្រសួងដែលដឹកនាំក្រុមការងារបច្ចេកទេសចម្រុះ ត្រូវរៀបចំសូចនាករតាមដានរួមគ្នា និងតាមដានការអនុវត្តសូចនាករទាំងនេះ ។ ដោយសហការជាមួយ គ.ជ.នា/ក.អ.ក និងក្រសួងផែនការ ក្រសួងនិងស្ថាប័នត្រូវពិនិត្យព័ត៌មានទាំងឡាយដែលបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានរបស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ជាធាតុចូលក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ ។

## ៧- ការតាមដាន និងវាយតម្លៃ

### ក- <u>ការផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍កម្រិតជាតិ និងកម្រិតវិស័យ</u>

រាជរដ្ឋាភិបាលបានចាត់ទុកថា ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ ដែលបានកំណត់ក្នុង**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣** ។ ក្នុងន័យនេះ គោលដៅចម្បងនៃក្របខណ្ឌតាមដាន ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ គឺការកំណត់សកម្មភាពនានាដែលត្រូវអនុវត្ត សម្រាប់ពង្រឹងភាពជាដៃគូដើម្បីឈានទៅសម្រេចបានលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។ នៅកម្រិតវិស័យ និងអន្តរវិស័យ ក្រោមកិច្ចសម្របសម្រួលរបស់ គ.ជ.នា/ក.អ.ក និងការតាមដានរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ សូចនាករតាមដានរួមគ្នា ដែលបានកំណត់សម្រាប់រយៈពេល ៥ ឆ្នាំ ស្របតាមអាណត្តិកាលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាឧបករណ៍សម្រាប់វាយតម្លៃភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ។ លើមូលដ្ឋាននៃក្របខណ្ឌលទ្ធផលរបស់វិស័យ ក្រសួង និងស្ថាប័នសាមី នឹងរៀបចំសូចនាករតាមដានរួមគ្នា នាដើមឆ្នាំ ២០១៤ ដើម្បីរួមចំណែកក្នុងការអនុវត្តឱ្យបានសម្រេច នូវបណ្តាគោលដៅអភិវឌ្ឍន៍ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ លើសពីនេះ ក្រុមការងារបច្ចេកទេសចម្រុះ នឹងរៀបចំសកម្មភាពប្រចាំឆ្នាំ និងសូចនាករ សម្រាប់ជាមូលដ្ឋាននៃកិច្ចពិភាក្សារបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងគោលដៅឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។

## ខ- ការតាមដានភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍

គុណភាព និងភាពស័ក្តិសិទ្ធិនៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ មានឥទ្ធិពលយ៉ាងធំធេង ទៅលើការអនុវត្តឱ្យបានសម្រេច នូវសូចនាករតាមដានរួមគ្នា និងគោលដៅអភិវឌ្ឍន៍ជាតិ ។ ក្នុងស្មារតីនេះ សូចនាករតាមដានរួមគ្នា គឺជាការបញ្ជាក់អំពីលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ដែលស្តែងចេញតាមរយៈសូចនាករនៃភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ។

តារាងខាងក្រោម បានរំលេចនូវសូចនាករ ១០ និងសកម្មភាពមួយចំនួន ដែលត្រូវអនុវត្តនៅកម្ពុជា ៖

| សូចនាករ | | ការតាមដានកម្រិតជាតិ | សកម្មភាពដែលត្រូវអនុវត្តនៅកម្ពុជា |
|---|---|---|---|
| ១ | ការប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិ ដោយដៃគូអភិវឌ្ឍន៍ | ✓ | - សំណួរនេះត្រូវបានរំលេចបន្ថែម ក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (ចំលើយ ៖ មាន/គ្មាន នៅតាមគម្រោងនីមួយៗ)<br>- កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់តាមដានការប្រើប្រាស់ក្របខណ្ឌលទ្ធផល<br>- ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ |
| ២ | បរិស្ថានអំណោយផល សម្រាប់អង្គការសង្គមស៊ីវិល | | - ប្រើប្រាស់ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ<br>- ការវាយតម្លៃពាក់កណ្តាលអាណត្តិ ដើម្បីពិនិត្យឡើងវិញ ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល<br>- កិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល |
| ៣ | ការរួមចំណែករបស់វិស័យឯកជនក្នុងកិច្ចអភិវឌ្ឍន៍ | | - ប្រើប្រាស់ព័ត៌មានក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ |
| ៤ | ការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | | - ធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងហិរញ្ញប្បទានរបស់អង្គការមិនមែនរដ្ឋាភិបាល ចំនួន ២ ដង ក្នុងមួយឆ្នាំ |
| ៥ | ភាពអាចទស្សន៍ទាយបាន នូវហិរញ្ញប្បទានសហប្រតិបត្តិការ ៖<br>ក- ប្រចាំឆ្នាំ៖ ការបើកផ្តល់ហិរញ្ញប្បទាន ធៀបនឹងផែនការ<br>ខ- រយៈពេលមធ្យម ៖ %នៃការបើកផ្តល់ហិរញ្ញប្បទាន ធៀបនឹងផែនការ | ✓ | - ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (ប្រៀបធៀបរវាងផែនការជាមួយការបើកផ្តល់ជាក់ស្តែង)<br>- ទំហំហិរញ្ញប្បទានគិតជាដុល្លារ និង %នៃគម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលបានបញ្ជាក់អំពីផែនការចំណាយសម្រាប់រយៈពេលខាងមុខ |
| ៦ | ទំហំហិរញ្ញប្បទានកត់ត្រាក្នុងថវិកា និងអនុម័តដោយរដ្ឋសភា | ✓ | - ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់រាយការណ៍ជូនរាជរដ្ឋាភិបាល<br>- របាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៧ | គណនេយ្យភាពទ្វេទិស (ការវាយតម្លៃរួមគ្នាលើវឌ្ឍនភាព) | ✓ | - របាយការណ៍របស់ក្រុមការងារបច្ចេកទេសចម្រុះ និងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា នៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ |
| ៨ | សមភាពយេនឌ័រ (%នៃប្រទេសដែលមានប្រព័ន្ធសម្រាប់កត់ត្រាការវិភាជន៍ធនធាន) | | - ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (វិស័យយេនឌ័រ និងចំណុចពាក់ព័ន្ធ)<br>- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីក្នុងវិស័យយេនឌ័រ ៖ របាយការណ៍របស់ក្រសួងកិច្ចការនារី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៩ | ប្រសិទ្ធភាពខាងស្ថាប័ន<br>ក- គុណភាពនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ<br>ខ- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្មជាតិ | ✓ | - CPIA (ការវាយតម្លៃពីខាងក្រៅ)<br>- របាយការណ៍នៅកម្រិតគម្រោងក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ អាចបញ្ជាក់អំពីកម្រិតនៃការប្រើប្រាស់ប្រព័ន្ធជាតិ |
| ១០ | ហិរញ្ញប្បទានភ្ជាប់លក្ខខណ្ឌ | | - របាយការណ៍នៅកម្រិតគម្រោងក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ |

ក្នុងការអនុវត្តគោលការណ៍ និងឧបករណ៍ ដើម្បីឈានទៅសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ គោលដៅចម្បង និងទិសដៅត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត និងតាមដាន តាមរយៈការរៀបចំក្របខណ្ឌតាមដានសម្រាប់រយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ ២០១៤ តទៅ ។

សូចនាករត្រូវបានដកស្រង់ចេញពីសូចនាករកម្រិតសកល សម្រាប់តាមដានវឌ្ឍនភាពនៃការអនុវត្តភាពជាដៃគូទីក្រុងប៊ូសាន និងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ព្រមទាំងផែនការសកម្មភាពទីក្រុងអាក្រា ។ ក្នុងបរិការណ៍កម្ពុជា សូចនាករចំនួន ១០ ត្រូវជ្រើសរើសសម្រាប់តាមដានវឌ្ឍនភាពនៃភាពជាដៃគូ ក្នុងនោះ សូចនាករ ៥ ត្រូវតាមដាននៅកម្រិតសកល ហើយសូចនាករ ៥ ទៀតត្រូវតាមដាននៅកម្រិតប្រទេស ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានកំណត់ទិន្នន័យជាមូលដ្ឋាន និងគោលដៅសម្រាប់សូចនាករនីមួយៗ តាមរយៈការចូលរួមរបស់កម្ពុជាក្នុងការធ្វើអង្កេតកម្រិតសកល ដែលបានប្រព្រឹត្តទៅ ក្នុងត្រីមាសទី ៣ ឆ្នាំ ២០១៣ កន្លងមក ។ លើមូលដ្ឋាននេះ គ.ជ.នា/ក.អ.ក ដឹកនាំកិច្ចសម្របសម្រួល សម្រាប់រៀបចំសកម្មភាពប្រចាំឆ្នាំ ដោយសហការជាមួយក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្ម និងភាពជាដៃគូ ។

| ***ទិសដៅជាយុទ្ធសាស្ត្រ និងគោលដៅ ព្រមទាំងសូចនាករសម្រាប់លើកកម្ពស់ភាពស័ក្តិសិទ្ធិនៃកិច្ចអភិវឌ្ឍន៍នៅកម្ពុជា*** | | |
|---|---|---|
| ***<u>គោលដៅចំបង</u>***<br>ធនធានសហប្រតិបត្តិការ ត្រូវបានប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍កម្ពុជា | ***ការត្រួតពិនិត្យ***<br>***សូចនាករ*** : ការតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដានរួមគ្នានៅកម្រិតវិស័យ សម្រាប់រយៈពេល ៥ ឆ្នាំ ២០១៤-២០១៨ គឺជាមូលដ្ឋានក្នុងការវាយតម្លៃប្រសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍ (ធាតុចេញ និងលទ្ធផល) ។ | ***ការវាយតម្លៃ***<br>ដើម្បីបំពេញឱ្យការត្រួតពិនិត្យ និងចែករំលែកបទពិសោធន៍ រាជរដ្ឋាភិបាលរៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តយុទ្ធសាស្ត្រស្តីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ក្នុងឆមាសទី ១ ឆ្នាំ ២០១៦ ។ |
| ***<u>ទិសដៅទី ១</u>***<br>ធនធានក្រៅប្រទេសត្រូវបានប្រើប្រាស់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងចីរភាពនៃកិច្ចអភិវឌ្ឍន៍ | **សូចនាករ**<br>១.ក- ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ក្របខណ្ឌជាតិស្តីពីលទ្ធផល (ទិន្នន័យជាមូលដ្ឋាន និងគោលដៅ: កំណត់នៅពេលក្រោយ)<br>១.ខ- ទំហំហិរញ្ញប្បទានផ្តល់តាមអភិក្រមគ្រប់គ្រងទូទាំង កម្មវិធី (ទិន្នន័យជាមូលដ្ឋាន: ២៨% និងគោលដៅ: ៥០%) | ការវាយតម្លៃយុទ្ធសាស្ត្រនេះ ដែលអាចភ្ជាប់ជាមួយនឹងការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងត្រូវដំណើរការ តាមរយៈការពិគ្រោះយោបល់ ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ។ ការវាយតម្លៃនឹងពិនិត្យអំពីទំនាក់ទំនងរវាងសកម្មភាពស្តីពីភាពស័ក្តិសិទ្ធិនៃកិច្ចអភិវឌ្ឍន៍ និងឥទ្ធិពលរបស់សកម្មភាពទាំងនេះ ទៅលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ |
| ***<u>ទិសដៅទី ២</u>***<br>ភាពជាដៃគូត្រូវផ្តោតលើការអភិវឌ្ឍសមត្ថភាព និងការពង្រឹងប្រព័ន្ធជាតិ | **សូចនាករ**<br>២.ក- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ទិន្នន័យជាមូលដ្ឋាន: ៣២% និងគោលដៅ: ៥០%)<br>២.ខ- ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (ទិន្នន័យជាមូលដ្ឋាន: ២០% និងគោលដៅ: ៣៥%) | |
| ***<u>ទិសដៅទី ៣</u>***<br>តួអង្គអភិវឌ្ឍន៍ទាំងអស់ នឹងចូលរួមក្នុងយន្តការនៃភាពជាដៃគូ ដើម្បីជំរុញកំណើន លើមូលដ្ឋានទូលំទូលាយ និងប្រកបដោយសមធមិ | **សូចនាករ**<br>៣.ក- ហិរញ្ញប្បទានកត់ត្រាក្នុងថវិកា (ទិន្នន័យជាមូលដ្ឋាន: ៧៩% និងគោលដៅ: ៩០%) និងបានបើកផ្តល់តាមកាលបរិច្ឆេទកំណត់ (ទិន្នន័យជាមូលដ្ឋាន: ៩១% និងគោលដៅ: ៩៥%)<br>៣.ខ- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ និងវាយតម្លៃរួមគ្នា អំពីវឌ្ឍនភាពរួមទាំងសូចនាករតាមដានរួមគ្នា | ឧបករណ៍ និងយន្តការពិគ្រោះយោបល់ដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ នឹងត្រូវពិនិត្យឡើងវិញ ដើម្បីធានាភាពត្រឹមត្រូវ និងប្រសិទ្ធភាព ព្រមទាំងកែលម្អឧបករណ៍និងយន្តការទាំងនេះ ក្នុងករណីចាំបាច់ ។ |

ផ្អែកតាមយន្តការតាមដានកម្រិតសកល ក្របខណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់អនុវត្តឱ្យបានសម្រេច នូវគោលដៅចម្បង និងទិសដៅជាយុទ្ធសាស្ត្រ ត្រូវបានកំណត់ក្នុងតារាងខាងក្រោម ។ សូចនាករចំនួន ៦ នឹងត្រូវប្រើប្រាស់សម្រាប់តាមដានវឌ្ឍនភាពនៃភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ក្នុងនោះ សូចនាករចំនួន ៥ ត្រូវបានដកស្រង់ចេញពីក្របខណ្ឌតាមដានសកលនៃ «ភាពជាដៃគូទីក្រុងប៊ូសានស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព» និងសូចនាករមួយទៀត គឺសូចនាករ ១.ខ ពាក់ព័ន្ធនឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ត្រូវតាមដានបន្តក្នុងក្របខណ្ឌនៃ «សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ» ។

## គ-__វិធីសាស្ត្រសម្រាប់រៀបចំរបាយការណ៍ស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយតម្លាភាព__

នៅក្នុងករណីទាំងអស់ រាជរដ្ឋាភិបាលអាចតាមដានវឌ្ឍនភាពនៃការអនុវត្តសូចនាករខាងលើ តាមរយៈការប្រើប្រាស់ប្រព័ន្ធទិន្នន័យដែលមានស្រាប់ ដូចជា ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្ពុជា ដែលធ្លាប់បានប្រើប្រាស់ សម្រាប់តាមដានការអនុវត្ត**សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស** នាឆ្នាំ ២០០៨ និងឆ្នាំ ២០១១ និងការធ្វើអង្កេតអំពីវឌ្ឍនភាពនៃការអនុវត្ត**ភាពជាដៃគូទីក្រុងប៊ូសាន ស្តីពីប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍** ។ លើមូលដ្ឋាននេះ សម្រាប់កម្ពុជា ការតាមដានវឌ្ឍនភាពក្នុងការអនុវត្តសូចនាករស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ទាំងសូចនាករកម្រិតជាតិ ទាំងសូចនាករកម្រិតសកល មិនបានបង្កើតបន្ទុកការងារធ្ងន់ធ្ងរបន្ថែម ដល់រាជរដ្ឋាភិបាល និងមិនតម្រូវឱ្យបង្កើតប្រព័ន្ធតាមដានថ្មីឡើយ ។ ប៉ុន្តែ ការងារនេះតម្រូវឱ្យដៃគូអភិវឌ្ឍន៍ បន្តផ្តល់ព័ត៌មានស្តីពីការប្រើប្រាស់ហិរញ្ញប្បទាន ចំនួន ២ ដង ក្នុងមួយឆ្នាំ គឺ ក្នុងត្រីមាសទី ១ និងទី ៣ តាមរយៈការធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ របស់ គ.ជ.ន/ក.អ.ក ។

ដើម្បីធានាតម្លាភាពពេញលេញ ព័ត៌មានទាំងឡាយស្តីពីហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល នឹងត្រូវបន្តផ្សព្វផ្សាយជាសាធារណៈ តាម**ប្រព័ន្ធអនឡាញ** ក្នុងគេហទំព័ររបស់ គ.ជ.ន/ក.អ.ក ។ កិច្ចការនេះមានសារៈសំខាន់ សម្រាប់សម្រួលដល់ការរៀបចំផែនការរបស់បណ្តាក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ទន្ទឹមនឹងការសម្របសម្រួលការងាររបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។ លើសពីនេះ រាជរដ្ឋាភិបាលជំរុញលើកទឹកចិត្តឱ្យគ្រឹះស្ថានសិក្សា និងប្រជាពលរដ្ឋ ប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះ សម្រាប់ការស្រាវជ្រាវផ្ទាល់ខ្លួន ក៏ដូចជាចែកផ្សាយព័ត៌មានជាសាធារណៈ ។

រាជរដ្ឋាភិបាលនឹងបន្តរៀបចំរបាយការណ៍វិភាគ គឺ**របាយការណ៍ស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍** សម្រាប់ពិភាក្សាក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ឬ វេទិកាអភិវឌ្ឍន៍កម្ពុជា ។ ទន្ទឹមនឹងនេះ ក៏បន្តរៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា សម្រាប់កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផងដែរ ។ លើសពីនេះ គ.ជ.ន/ក.អ.ក នឹងបន្តរៀបចំរបាយការណ៍ដទៃទៀត ដូចជាការវិភាជន៍ និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ និងវឌ្ឍនភាពក្នុងការអនុវត្តការប្តេជ្ញានានា ដែលមានចែងក្នុង**ភាពជាដៃគូទីក្រុងប៊ូសានស្តីពីប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍** ដើម្បីលើកកម្ពស់កិច្ចសម្របសម្រួល និងការវិភាជន៍ធនធានសហប្រតិបត្តិការ ឱ្យកាន់តែមានប្រសិទ្ធភាព ។

### ឃ- ការវាយតម្លៃពាក់កណ្តាលអាណត្តិ

ដើម្បីបំពេញបន្ថែមឱ្យការតាមដានវឌ្ឍនភាព រាជរដ្ឋាភិបាលនឹងធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដោយមានការចូលរួមពីតួអង្គអភិវឌ្ឍន៍ទាំងអស់ នៅពាក់កណ្តាលឆ្នាំ ២០១៦ ដើម្បីពិនិត្យវឌ្ឍនភាព និងដកស្រង់បទពិសោធន៍ ។ ការវាយតម្លៃនេះនឹងត្រូវអនុវត្តស្របពេលនឹងដំណើរការនៃការត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែរ ។ ក្នុងគោលដៅបន្តគាំទ្រដល់កិច្ចប្រឹងប្រែងរបស់កម្ពុជា និងពង្រឹងការអនុវត្តភាពជាដៃគូកម្រិតសកលនៃសេចក្តីថ្លែងការណ៍ទីក្រុងប៊ូសាន ការវាយតម្លៃនេះនឹងត្រូវដំណើរការ តាមរយៈកិច្ចពិភាក្សាជាមួយក្រុមការងារបច្ចេកទេសចម្រុះស្តីពីសុខដុមនីយកម្ម និងភាពជាដៃគូ ដោយផ្តោតការយកចិត្តទុកដាក់ ដល់កត្តាសំខាន់ៗមួយចំនួន ដូចជា របៀបវារៈស្តីពីភាពជាដៃគូកម្រិតសកលសម្រាប់ដំណាក់កាលក្រោយឆ្នាំ ២០១៥ កាលានុវត្តភាពសម្រាប់ការរៀបចំ និងការតាមដានអនុវត្តគោលនយោបាយដទៃទៀត ព្រមទាំងកាលបរិច្ឆេទ និងសារៈប្រយោជន៍នៃដំណើរការវាយតម្លៃនេះផងដែរ ។

ទន្ទឹមនឹងនេះ ជាមួយនឹងទស្សនវិស័យរយៈពេលវែង និងដោយផ្អែកលើរបៀបវារៈក្រោយឆ្នាំ ២០១៥ ការវាយតម្លៃនេះ ក៏អាចផ្តោតការយកចិត្តទុកដាក់ខ្ពស់ ទៅលើបរិស្ថានខាងក្រៅដែលពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងអាទិភាពអភិវឌ្ឍន៍កម្ពុជា ក្នុងខណៈដែលប្រទេសនេះ ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដើម្បីកម្ពុជាអាចត្រៀមលក្ខណៈបានជាមុន នៅពេលមានការប្រែប្រួល ទាំងខាងអាទិភាពអភិវឌ្ឍន៍របស់កម្ពុជា ទាំងខាងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ។

### ង- ការតាមដាននៅកម្រិតវិស័យ និងគម្រោង

ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ នៅកម្រិតវិស័យ និងអន្តរវិស័យ រាជរដ្ឋាភិបាលអាចបង្កើតឧបករណ៍ថ្មីបន្ថែមទៀត ក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីរំលេចអំពីក្របខណ្ឌលទ្ធផលជាក់លាក់របស់វិស័យ ដែលត្រូវផ្សារភ្ជាប់នឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ផ្អែកលើសូចនាករតាមដាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលអាចតាមដានការអនុវត្ត និងការរួមចំណែកនៃគម្រោងរបស់ដៃគូអភិវឌ្ឍន៍ សំដៅឈានទៅសម្រេចគោលដៅរបស់វិស័យ ។ លើសពីនេះ តាមសំណើពីក្រសួង និងស្ថាប័ន ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនេះក៏អាចរៀបចំតាមអនុវិស័យនីមួយៗ ស្របតាមផែនការ និងថវិការបស់វិស័យនីមួយៗផងដែរ ។

ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ដោយផ្អែកលើផែនការប្រចាំឆ្នាំ និងក្របខណ្ឌលទ្ធផលរបស់វិស័យខ្លួន ។ ជាមួយគ្នានេះ ការវាយតម្លៃរួមគ្នា អំពីវឌ្ឍនភាពគម្រោង ដើម្បីរួមចំណែកសម្រេចលទ្ធផលជាក់លាក់របស់វិស័យ ក៏អាចផ្តល់មេរៀន និងបទពិសោធន៍ សម្រាប់ពិគ្រោះយោបល់កម្រិតគោលនយោបាយ និងរៀបចំកម្មវិធីអភិវឌ្ឍន៍ នាអនាគត ។ ក្នុងន័យនេះ ទន្ទឹមនឹងការកត់ត្រាធាតុចូលរបស់គម្រោងនីមួយៗ ការតាមដាន និងវាយតម្លៃរួមគ្នា អាចរំលេចអំពីការរួមចំណែករបស់គម្រោងនីមួយៗ ក្នុងការឈានទៅសម្រេចលទ្ធផល ទាំងនៅកម្រិតវិស័យ ទាំងនៅកម្រិតជាតិ ។

## ៨- សេចក្តីសន្និដ្ឋាន

វឌ្ឍនភាពឆាប់រហ័សក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា និងក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាសមិទ្ធផលក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គឺជាសក្ខីកម្មបង្ហាញពីភាពដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍នានា ទន្ទឹមនឹងការទទួលស្គាល់អំពីតួនាទី និងការរួមចំណែករបស់តួអង្គអភិវឌ្ឍន៍ដទៃទៀត ដូចជាដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ។ ដើម្បីបន្តពង្រឹងវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈម រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់ លើការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រស្តីពីភាពជាដៃគូ ។

លើមូលដ្ឋាននេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានកំណត់គោលដៅអភិវឌ្ឍន៍ជាក់លាក់ សម្រាប់តម្រែតម្រង់កម្ពុជា ឆ្ពោះទៅភាពជោគជ័យ និងវិបុលភាពបន្ថែមទៀត ក្នុងឋានៈជាប្រទេសមានចំណូលមធ្យម ។ ការអនុវត្តពេញលេញ នូវគោលការណ៍នានាដែលបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូបន្ថែមលើការអនុវត្តដោយជោគជ័យ នូវឧបករណ៍ទាំង ៤ គឺជាកត្តាសំខាន់ក្នុងការសម្រេចឱ្យបាន នូវគោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ គឺ**ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយភាពស័ក្តិសិទ្ធិ** និងផ្តល់ផលសម្រាប់រយៈពេលវែង ។

ដោយទទួលស្គាល់ទំនាក់ទំនងនៃភាពជាដៃគូ រវាងកម្រិតជាតិ និងកម្រិតសកល រាជរដ្ឋាភិបាលសូមបញ្ជាក់សារជាថ្មី ដល់តួអង្គអភិវឌ្ឍន៍ទាំងអស់ អំពីតម្រូវការនៃ**ភាពបំពេញឱ្យគ្នាទៅវិញទៅមក រវាងបណ្តាសកម្មភាពនានាសម្រាប់គោលដៅរួម** ដែលបានកំណត់ក្នុង**ភាពជាដៃគូនៃទីក្រុងប៊ូសានស្តីពីប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍** ។ ភាពជាដៃគូប្រកបដោយបរិយាប័ន្ន រវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ដូចបានលើកឡើង ក្នុងវេទិកាទីក្រុងប៊ូសាន ត្រូវបានរំលេចក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ស្របតាមបរិការណ៍របស់កម្ពុជា ។ ដោយទទួលស្គាល់អំពីមុខជំនាញ និងការរួមចំណែករបស់តួអង្គអភិវឌ្ឍន៍នីមួយៗ យើងទាំងអស់គ្នាចាំបាច់ត្រូវបំពេញការងារ ក្នុងក្របខណ្ឌលទ្ធផលរួមតែមួយ សម្រាប់តម្រែតម្រង់គ្រប់សកម្មភាព និងហិរញ្ញប្បទានរបស់តួអង្គអភិវឌ្ឍន៍ទាំងអស់ សំដៅឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។

សកម្មភាពទាំងឡាយ ដែលបានរំលេចក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ គួបផ្សំជាមួយការគាំទ្រខាងធនធាន ត្រូវអនុវត្តនៅ ២ កម្រិត : ១- នៅ គ. ជ. ន/ក. អ. ក និង ២- នៅកម្រិតវិស័យតាមរយៈក្រសួង និងស្ថាប័ន និងនៅថ្នាក់ក្រោមជាតិ ។ ក្នុងន័យនេះ ដៃគូអភិវឌ្ឍន៍ត្រូវបន្តផ្តល់ហិរញ្ញប្បទាន និងការគាំទ្ររបស់ខ្លួន ដល់ គ. ជ. ន/ក. អ. ក និងក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីអនុវត្ត និងតាមដានការអនុវត្តយុទ្ធសាស្ត្រនេះ ។ ផ្អែកលើក្របខណ្ឌលទ្ធផលដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ ការបន្តកិច្ចពិភាក្សា និងដកស្រង់បទពិសោធន៍រួមគ្នា នឹងអាចជួយដោះស្រាយបញ្ហាប្រឈម និងទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពថ្មីៗរបស់កម្ពុជា ដើម្បីឈានទៅសម្រេចភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ដែលជាគោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ ។